ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូសុវណ្ណញាណ សួរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* ទំព័រ

លោក ហេង-យ៉ាន់ — កំពូលស្នេហា (តមក) . . . . . . . . . ៣៣៩

យុន សុន្ទរមេធី ញូង-សៀង — ដកស្រង់រាត្រី ភាគទី ១ (តមក) . . . . ៣៥០

ហួងនិពន្ធមន្ត្រី ញ៉ុក-ថែម — ព្រះរាជប្រវត្តិ ព្រះបាទសម្ដេចព្រះជ័យជេស្ឋា (ព្រះអង្គសួរ) (តមក) . . . . . . . . . ៣៦៧

*ផ្នែកសាសនា*

ព្រះគ្រូមហាបទុម មាឃ-ស៊ុន — ឥន្ទវគ្គបរិយាយ (តមកនិងចប់) . . . . . ៣៨៥

ឆ្នាំទី ១៨ — លេខ ៣ ខែស៊ីយេក ១៩៤៦ — ដំឡៃជាវៈ ១ ឆ្នាំ ៣៥ រៀល ។
1946

## កាំភួសស្នេហា

## លោកហេង-យ៉ាន់ រៀបរៀង

(តមក)

### វគ្គទី ៧

### ចូលស្រឡះក្នុងឆ្នាំថ្មី

មាន់ទើបនឹងទទះស្លាបរងាវតាមយាមពម្នា   តែពួកបក្សាបក្សីមិនបានផើតាំសំពួសញ្ញានោះឡើយ   បានក្រោកចេញពាកទ្រនំយូរក្រែលវែងហើយ   ដោយហេតុថ្ងៃកខុសទំនៀម,   តែវាំនាំគ្នាចាំស្រៀមនៅរហាន់លើមែកឈើផើតាំពន្លឺថ្ងៃ ៗ លុះដល់បែកបបួសសម័យ ស្រីព្រះសុរ្យាក៏ព្រោងព្រោតផាលប្រាក់ឯទិសបូព៌ាទពណ៌ក្រហមព្រាល ១ ដូចសម្បុរនៃទារក,   ដល់បុព្វណ្ហសម័យ ព្រះអាទិត្យក៏លេចឡើងស្រឡះច្បាស់ចេញពេញវង់លើខ្នងព្រៃក្បា   ចាំងពន្លឺថ្លាប្រាសចាកមន្ទិល   ហាក់ដូចឧបត្តិឡើងជាគ្រាដំបូង បញ្ចាំងដំណក់សន្សើមដែលជាប់លើស្លឹកឈើឲ្យភ្លឺផ្លេកខ្លួតាំងនៃផ្ទៃប្រថពី   គួរជាទីកេកយដល់មនុស្សនិងសត្វទាំងឡាយហើយស្រូបយកដំណក់ទឹកនោះព្រមទាំងល្អងធូលីទៅផង   សំអាតធម្មជាតិទាំងមូលឲ្យដូចបឋមហេតុនៃស្ថានលោក   ពេលព្រឹកព្រលឹមគាជាកំដបំព្រងដោយស្លឹកទើបនឹងលូតលាស់ខៀវស្រងាត់   ចំណែកពួកសត្វស្លាបដែលហើរចេញលាត់ឯវហាស៍ សំដែងសេចក្តីត្រេកអរចំពោះព្រះអាទិត្យ

ទុំទះស្លាបប្រកបទៅដោយពេមទន់ល្ហើយ ឯសួនបុប្ផាក៏ប្រែស់ព្រៃទៅដោយ បុប្ផាពីរព័ណ៌ ចោលក្លិនឈួយឈ្ងប់ក្រអូបអប់ឯកាកាសនភាល័យ ។

ព្រឹកនោះ បួនវ៉ែតពន្លឺរៀងរនាន់ ក្តីបុប្ផាស់ ។ ហាក់ដូចជាសប្បាយខ្លាំងណាស់ អ្នកណាក្តីហើយក៏មានចិត្តជ្រះថ្លារីករាយងើយមុខទម្រៀងមើលមេឃ ហើយត្រាស់ដៃទោយមិនដឹងជាបង់បានអ្វីសោះ ដូចក្មេងទើបនឹងចេះដើរ ។ តាមផ្លូវ មានមនុស្សដើរហូរហែទាំងព្រលឹម មុខស្រស់ញញឹមប្រិយប៉ាក់ក្នែងខ្លួនស្អាតបាតយ៉ាងហ៊ឺហា . ពួកកុមារីមានផ្កាបម្យាសៀតសក់ឬស្រួននីមួយៗកាន់នៅនឹងដៃ រីឯក្រមៀកក៏ហោលទូរពន្លឺជេញផ្សេងៗ ព្រោះចេញពីត្បូងទាំងគ្រាប់ធំព្រំប្រហៀង ។ អ្នកស្រុកទាំងអស់គ្នាកតសល់ទានដល់រូបណាមួយ គ្រប់រ័យ គ្រប់ភេទ ថ្ងៃនោះឯងតែងខ្លួនស្លៀកពាក់ដោយគ្រឿងប្រដាប់ស្អាតតែប៉ុណ្ណាំងអស់ មុខនេះតែពីស្រស់មិនដែលក្រៀមដល់មួយនាទី . អ្នកមានទុក្ខក្លាយទៅជាសប្បាយវិញ អ្នកមានជម្ងឺក៏បានស្រាកស្រាន្ត អ្នកកំសត់ទុគ៌តក៏ពុំមាន សមយោបចក៏អន្តរធានបាត់ពីផ្ទៃផែនដី លែងប្រែប្រួលតាមផ្លូវដូចថ្ងៃឯទៀត ចំណែកឯសត្វនានាឈ្មួញក្រោចឆ្ងាត់ទៅមកដោយសេចក្តីសប្បាយភ្នែកកើតកើយ បក្សីសត្វក៏បានឈប់សំកកខ្លួន ។ ទាំងនេះមិនដឹងជាដោយអំណាចបុណ្យ-ឫកោរូបយ៉ាងណាទេ សេចក្តីសុខមនោរម្យបានចុះមកសណ្ឋិតលើផ្ទៃលោក

វិស័យដូចកាលដែលព្រះរាមយានវិលមកពីធ្វើយុទ្ធសង្គ្រាមជាមួយនឹង ក្រុងរាពណ៍វិញក្នុងរឿងរាមាយណៈ របស់វាល្មិក ។

គ្រឹះស្ថានទាំងប៉ុន្មានក្នុងទីក្រុងផ្លាស់ការ ក្រៅពីជញ្ជាំងលាបពណ៌ឡើងវិញ គួរជាទីគាប់ចិត្ត ។ វិថីផ្លូវហុយ ទៅលោមចេញពីត្រើបទាក់ទ្វារ ផ្ទះអណ្តែតផល់ការការសវិមានទេវតា ទីនពន្ធទៀនព្រានព្រាត បំភ្លឺក្រុមញាតិ បំភ្លឺមុខឲ្យស្រស់ស្រស់ផ្ទូវផង់ ។ តាមរបៀងផ្ទះសំណាងតាមយោលរយោងគួរឲ្យគន់ ។ ពុម្ពជាដែលចាំងមូលបំផុតឲ្យនឹងផ្ទុះចេញពីផ្ទៃផែនដីបុ ដូចកាលក្រុងគោកដូចកំប្រុក្កតិឡើងកណ្តាលសាគរមហាសមុទ្រ នៅចុងបូព៌ាប្រទេសជាយថុទ្ធិមហាពជក្ជុដ្ឋនាគពជ កាលសម័យព្រះបាទកជា ។ ឯបាដិហារ្យដ៏ចម្លែកអស់នេះគឺចេញពីដួងមង្គលនៃជនទាំងឡាយ ដែលមានបោតុឲ្យដឹងនៅជាប់នឹងនៅនឹងចាំងបន្ទុំ គឺអក្សរចារ៉ាកជាភ្ជាថា :

"ចូលឆ្នាំថ្មី" ព្រមទាំងពាក្យសព្ទសាធុការ :

"អាយុ វណ្ណៈ សុខៈ ពលៈ"

ព្រឹកនោះមានធ្វើពលីការបូជាទេវតាថ្មី ដែលយាងចុះមកស្ថិតលើផ្ទៃលោកជានុឡាកេ ។

បំណែកពួកកំឡោះកល់រូប សៀកពាក់ហុំហាវៃនវិនការរបៀបរបស់គេ ដែលយើងបានឃើញនឹងភ្នែកស្រាប់ហើយ មិនចាំបាច់អធិប្បាយក្នុងទីនេះទៀតទេ គ្រាន់តែបញ្ជាក់ថា យុវជនទាំងនោះនាំគ្នា

ត្រសឹងឆ្ពោះទៅឯទីផ្សារ ដែលចិញ្ចឹមដល់ប្រែក្លាយជាសួនបុប្ផា រៀងកាយ
ត្រូវឲ្យបាប់ក្លែក ហើយកំឡោះទាំងនោះនាំគ្នារើសបាច់ផ្កាតាមសេចក្ដីប៉ុន-
ប៉ងរៀងខ្លួន តាមតែអ្នកអស់នោះមានចិត្តប្រាថ្នាថែបណា បុប្ផាទាំងនោះ
ក៏ជម្រើឲ្យត្រូវចិត្តទាំងអស់ ផ្កាគ្រប់ពណ៌មានលាយស្ទើរផងជាសញ្ញានៃ
សេចក្ដីសុខសប្បាយសម្បូរសម្បត្តិ សំរាប់យកទៅជូនដល់អ្នកធំ មាន
ត្រូបាអាចារ្យជាដើម ចំណែកផ្កាច័ន្ទក្ដូសតំបក់ក្លិនក្រអូបសាយយ៉ាងមង
ជាក់ច្បូ ហើយនៅរីកបានយូរគេបន្តគ្នាជាទីគាប់ចិត្តនៃកំឡោះដែលមានគូ
ព្រោះជាគ្រឿងសំដែងនៃសេចក្ដីបរិសុទ្ធចិត្តរបស់គេនិងសេចក្ដីស្មោះត្រង់
ជានិច្ចនិរន្តរ៍ ឯផ្កាកុឡាបដែលអ្នកផងនិយមថាជាផ្កាល្អគេតតាយជាង
អស់ទាំងផ្កាក្នុងលោក ដែលអ្នកស្រុកគ្រប់ប្រទេសលើកដម្កើងជាបុប្ផា
ថ្លៃថ្លាបំផុត មានសម្បុរស្រស់យ៉ាងស្រទន់ដល់ក្លែក ជាការសរសើរ
ចំពោះក្រមុំព្រហ្មចារិនីដែលជាទីស្រឡាញ់ ៗ ផ្កាក្រអោកពណ៌ក្រហម
ប្លុលឿងចេត ប្រាប់ថាចិត្តបុរសនោះមានសេចក្ដីស្នេហាយ៉ាងខ្លាំងចំពោះ
នាង មានចិត្តចង់ចួបមុខនាងនិយាយសាសងដោយអត់ធន់ស្ទើរពុំបាន ៗ
ចំណែកចម្ប៉ាសដែលនាងតែងពាក់បន្ទក្រងសក់ មានន័យថាចង់បាន
នាងមកប៉ួបមជ្ឈក់ជួមនៅវេលាថ្ងៃ គឺត្រូវការយោធអាងជាគូជីវិតដោយមាន
មាតាបិតាដឹងឮផង ឯផ្កាម្លិក្រហមគឺចង់ចួបនឹងនាងនាវេលាយប់ស្ងាត់
មានពន្លឺព្រះបន្ទះព្រាងព្រាតនិងពន្លឺព្រះតារាផ្កាយ ៗ ពេញផ្ទៃមេឃ ៗ

ឯផ្កាក្រៅពីនោះ តាមទ្រង់ទ្រាយតាមពណ៌សម្បុរតាមកំឡុងរដូវ បានយូរឬឆាប់ ទាំងតាមពេលដែលលាតលា ស្រពាប់តែងមានន័យដោយខ្លួនៗ ពីគ្នា ដែលពួកកំឡោះបានយកមកប្រើទុកដូចជាសំបុត្រផ្ញើទៅពួកស្រីៗ ដើម្បីឲ្យណាត់សញ្ញាពេលម៉ោងខំសន្យា. ឬថ្លែងទឹកចិត្តរបស់ខ្លួនឲ្យនាងដឹងៗ

កាលបើបានចំណាន់ផ្កាទុកនៅដៃហើយ ពួកយុវជនទាំងនោះក៏នាំគ្នាដើរហែតាមផ្លូវ បីដូចជាទៅគោរពបូជនីយដ្ឋានឯណាមួយដែលគេបានប្រតិបត្តិរៀងរាល់ពេលមិនដែលឃ្លាតខានឆ្នាំណាមួយៗ អ្នកដែលមានគូយកផ្កាមកតុបជើបជូនសនាង ហើយបំណាន់នឹងឲ្យជាប់ក្លិនរបស់ខ្លួននឹងផ្កានោះ គ្រាន់តែដឹងថានាងមុខជានឹងយកផ្កា ដែលជាចំណែកមួយរបស់ខ្លួនឬមួយជាអ្នកដណ្ដឹងបណ្ដោះអាសន្ន មកទុកបរិតឲ្យជាប់នឹងសាច់របស់នាង ហើយក្លិនអ្នកទាំងពីរបានសម្ពន្ធចូលគ្នានោះ ក៏ត្រេកត្រអាលសន្ធឹកណាស់ទៅហើយ ដើរមិនមើលផ្លូវតែក្រសំឡឹងមើលទៅលើមេឃ ខំគិតប្រវត្តិដល់រូបធីតាដួងចិត្តៗ

ចុះសោកក្រអ្នកធ្វើអ្វីដែរនាវេលាថ្ងៃនោះ? ជាបញ្ហាដែលយើងផ្ដួងដោយមានៈដល់ចន្លែងនេះ, ពិតហើយជាសោកក្រគោរពសំដែងសេចក្ដីគោរពបូជាចំពោះអ្នកឯណាមួយ តែនឹងសំដែងអភិវន្ទនាការដល់ស្រ្តីឯណា? ចុះនឹងយកផ្កាទៅឲ្យណាផងនេត្រនារីឬអ្វី? សោកក្រក៏មាន

បំណាច់ធ្វើផ្លូវប្រោះដែរ គ្មានគំនិតថ្មីប្លែកក្រៅពីនោះទេ “ តែ...តែការ ទឹងទៅហើយ ” សោភ័ក្រ្តក៏កាន់ផ្កាដើរតាមផ្លូវដែម្រង់ទៅឯផ្ទះនារីថៃវៃ លួសហើយគិតថា “ ឱ បើប្រសិនជាបានឲ្យដល់ណុជនេត្រនារីវិញហ៎ា ! តែគំនិតនោះមិនធ្វើឲ្យសោភ័ក្រ្តរំភើបចិត្តឡើយ ព្រោះណុជនេត្រនារី ឃ្លាតពីសោភ័ក្រ្ត ឃ្លាតឆ្ងាយប៉ុនដូចមេឃនឹងដី មួយវិញទៀតវេលាបួល ឆ្នាំថ្មីមិនអនុញ្ញាតឲ្យមនុស្សលោកកើតទុក្ខ នឹកដល់អតីតរបស់ខ្លួន ។ ឯផ្កានោះសោភ័ក្រ្តរើសបែបដូចម្ដេចគួរយើងកត់ទុក ដើម្បីឲ្យដឹងច្បាស់ ដល់ទឹកចិត្តដ៏កំបាំងរបស់សោភ័ក្រ្ត ទុកជាសោភ័ក្រ្តយកចិត្តទុកដាក់មុន ដូចម្ដេចក្ដី ក៏ការរើសនោះលុះដោយសេចក្ដីបង្គាប់អំពីអំណាចមានកន្ទ មតដែរ ។

ផ្កាដែលសោភ័ក្រ្តបានរើសនោះ គួរឲ្យអន់ណាស់ បានតាន់នៅ ដៃហើយគួរឲ្យនឹកឃើញថា “ អ្នកដែលយកមកឲ្យនោះមាននិស្ស័យខាង ជើងសិល្ប ប៉ុន្តែផ្កានោះហាក់ដូចជាបេះទំលាយ យ៉ាងគ្រោះក្លាយដល់អ្នក ដែលបេះសង្កេត ។ គឺផ្កាខ្ទួនស្រីនៅកណ្ដាលជុំវិញមានបម្រាសបន្ទាប់មក ផ្កាក្រអៅកពណ៌លឿងខាងលើបង្អស់ កណ្ដាលខ្ទួនស្រី មានអៀតផ្កា បេកទេស ៗ លុះដល់ផ្ទះថៃវៃលួសហើយ សោភ័ក្រ្តក៏ចូលទៅរកនារី ជាទីពេញចិត្ត ហើយហុចផ្កាទៅឲ្យនាងដោយមានវាចាដូច្នេះ

“ប្អូន! នាគ្រាពេលឆ្នាំថ្មី បងគ្មានអ្វីជាទីគាប់ប្រសើរជូនអូនទេ មានតែក្ដានេះនិងទឹកចិត្តដ៏បរិសុទ្ធរបស់បងទុកជាទីរលឹកប៉ុណ្ណោះ ព្រោះបើមិនសមសួនជូននឹងសេចក្ដីគិតរបស់ប្អូនដូចម្ដេចក្ដី សូមប្អូនមេត្តាសន្ដោសដល់បងផងចុះ ដែលជាអ្នកទាល់ក្រណាស់សព្វថ្ងៃនេះ មួយវិញទៀតបងសូមជូនពរបួនប្រការដល់ប្អូន គឺសូមឲ្យប្អូនបានប្រកបដោយអាយុ វណ្ណៈ សុខៈ ពលៈ និងសូមឲ្យប្អូនមានសម្បត្តិបីប្រការ គឺយសសម្បត្តិ បរិវារសម្បត្តិ និងភោគសម្បត្តិ គ្រាន់នឹងបងសូមផ្ដែកកោនពឹងវាសនាប្អូនផង ពិតហើយជាសម្បត្តិទាំងបីនេះ និងពរខាងដើមនោះបរិបូណ៌ដល់រូបប្អូន ឯបងក៏ដឹងជាក់ច្បាស់ឥតសង្ស័យ ថាដូច្នោះពិត តែបងបន្ថែមឲ្យប្អូនស្ពិតស្គុកកើនជាងនោះបានរយភាគទៅទៀត ឯរូបបងវិញបងសូមតែសេចក្ដីមេត្តាពីប្អូនប៉ុណ្ណោះ” .... ។

បុត្រីថៃឮសព្ទពាក្យទាំងអម្បាលនោះហើយ ក៏ញញឹមយ៉ាងស្រស់ហើយសួរសោកក្ដៅឡើងថា :

“ថ្ងៃនេះប្រាជ្ញអីក៏ប្រាជ្ញម្ល៉េះ?”

“បងប្រាជ្ញឲ្យតែប្អូនអាណិតគេ” ។

“ចុះឲ្យខ្ញុំអាណិតអំពីរឿងអ្វី បងមានធ្វើអ្វីឲ្យត្រូវដល់ខ្ញុំ? ឯឆ្នាំនេះខ្ញុំត្រូវខ្វល់ដោយមេត្រីចិត្តហើយៗ ជាមិត្តដ៏មានដំឡៃបំផុតសំរាប់ខ្ញុំ កុំឲ្យបងតូចចិត្តអី” ។

ថាហើយនាងស្មៀមគេចមុខញញឹមយកផ្កាមកសង្កេតមើល នឹកឆ្ងល់ដល់សេចក្ដីត្រួតត្រាស់នៃផ្កានោះ តែមិនទាន់សម្រេចសេចក្ដីដូចម្ដេច ស្រាប់តែសោភ័ក្រ្តដើរមកជិតនាង ពោលពាក្យថាយ៉ាងក្រៀមក្រោះ តែគួរឲ្យខ្ទេចចិត្តដូច្នេះ:

"ប្អូន! អូនមេត្តាដល់បងមែនឬ? ប្អូនមិនគិតដល់សេចក្ដីទាល់ក្រ របស់បងទេ។ បងមានសេចក្ដីត្រេកអរពេកទំហំផុតគ្មាន ហើយបងមិនដឹងប្រតិបត្តិដូចម្ដេច ឲ្យជូននឹងអធ្យាស្រ័យដ៏ទូលាយត្រជាក់របស់ប្អូននោះឡើយ"។

នាងងាកមុខមកញញឹមនឹងសោភ័ក្រ្ត តែមិនបានបញ្ចេញសំដីថាអ្វី ចុះជាដូច្នេះ ក៏សោភ័ក្រ្តមើលទឹកចិត្តរបស់នាងបានតាមក្រសែភ្នែកដ៏ខ្មៅស្រស់ តែងតែដែលធ្លុះនូវពន្លឺសេចក្ដីស្នេហា។

ពេលនោះចៅវិស្សួសមកដល់ ឃើញកិរិយាទន់លំទោនរបស់អ្នកទាំងពីរ ចៅក៏ញញឹមហើយប្រើសោភ័ក្រ្តឲ្យជួយរៀបចាត់ចែកទឹកកក លីមូណាត់លៀងគ្រួសារ។

សោភ័ក្រ្តនៅលេងផ្ទះចៅវិស្សួសរហូតដល់ថ្ងៃរសៀល ទើបលាអ្នកម្ចាស់ផ្ទះដំណើរទៅគេហាឋាន។

ពេលនោះព្រះអាទិត្យជិតអស្តង្គត បានបញ្ចេញពន្លឺរស្មីលើផ្ទៃលោក ក្នុងចក្រវាឡក្រឡោងស្វាងហើយឯអាកាសជាក្រោះក្រាយ

បុប្ផសីនាថ្ងៃនោះ ដើម្បីទទួលពន្លឺថ្ងៃបួលព្រឹក ។ តាមផ្លូវមានត្រីបក្សាហើរបក្ខាក់ខ្លែង នៅគ្រប់តំបន់ ទទួលមនុស្សម្នាដើរដាសពោរពេញនៅសប្បាយ ។ ពួកឧបាសកឧបាសិកាដើរវត្ត នាំគ្នាអង្គុយប្រណម្យក្នុងព្រះវិហារស្តាប់ព្រះភិក្ខុសង្ឃសូត្រធម៌ ។ គ្រប់គារពមញ្ញកែ សូរស័ព្ទធម៌លាន់ត្រលួចពេញអាកាសបីដូចជាបទបំពេជស័ក្តិសិទ្ធិអាចនឹងបង្ក្រាបចិត្តមនុស្សឱ្យស្ងប់ស្ងាត់ មិនរវើរវាយដល់អារម្មណ៍ខាងក្រៅ ប្រុងតែយកចិត្តចំពោះព្រះរតនត្រ័យថ្ងៃឧត្តម ។

សោភ័ក្ត្រហាក់ដូចជាប៉ិកនៅកណ្តាលដែនយល់សប្តិ ដើរដល់ផ្ទះអាចារ្យឃើញផ្កាកុឡាបរីកយមានក្រពុំប៉ុបពងគ្រប់មែក ដែលពីខែមុននោះនៅតែទងទទេ លុះដល់មាត់ជណ្តើរ ឆ្កែញីរបស់អាចារ្យក៏ស្ទុះក្ពាមកទទួលសោភ័ក្ត្រដោយរាក់ទាក់ មើលមុខមេស្រុនខនោះហាក់ដូចជាសប្បាយខ្លាំងណាស់ ហើយរាំទើបនឹងព្រាត់ប្រាសកូនទៅពីប៉ុន្មានថ្ងៃមុននោះសោះ ។ សោភ័ក្ត្រក៏ទឹតធ្លល់បន្តិច ផល់ចូលទៅដល់រានហាលឃើញប្អូនស្រីអាចារ្យគាយុទើបនឹងបានប្រាំឆ្នាំ កំពុងឧបរូបកូនក្រមុំពីលេងហើយប្រាប់សោភ័ក្ត្រថា:

លោកបងទើបនឹងទិញរូបកូនក្រមុំនេះឲ្យនាង ល្អទេ មើលសក់រួញផង" ។

“ សោក្រ័តញញឹមឆ្លើយថា: “ ល្អហើយនាង ចុះនាងសែនស្តាយរូបកូនក្រមុំចាស់ហើយឬដែលជាប់ជាតិកំណត់មួយថ្ងៃណោះ?” ។

“ ទេ អានេះល្អជាង ” ។

សោក្រ័តតែតែឆ្ងល់ក្នុងចិត្ត តែមិនបានដៅសេចក្ដីដូចម្ដេចក៏ដើរចូលទៅក្នុង លុះដល់មាត់ទ្វារ ក្រឡេកមើលទៅឃើញណុងនេត្រនារី ទើបឈប់រើកនៅទីនោះ ស្រាប់តែនាងលាអាចារ្យវិលទៅផ្ទះវិញ ដល់ទ្វារនាងសូមផ្លូវសោក្រ័តចេញ សោក្រ័តភ្ញាក់ខ្លួនព្រើតណាក្រអូបទឹកអប់បុកច្រមុះ ងាកចេញហើយបានឲ្យសព្ទសាធុការដល់នាងថា :

“ សូមឲ្យនាងបាននូវសេចក្ដីសុខ ” ។

តែនាងមិនស្ដាប់ដើរចុះទៅ សោក្រ័តមិនបានជាកើតពីដល់អាការខុសទំនងនោះឡើយ ហើយក៏ដើរចូលទៅរកពីយ៉ាណូក៏ វែកគំនិតថ្មីភ្លាមឡើងថា:

“ ដើមកុឡាបដែលពោយកយសន្ធឹកនឹងផ្កា មិនមែនមានចិត្តដកបទេ គឺមិនប្រើប៉ុន្មានក៏នឹងតែសំខ្មួកទាំងផ្កាលួតលាស់ឡើងជាថ្មីវិញ មេសុនខ្ញុំដែលព្រាត់ខ្លួនទៅ ធ្លាប់ប្រើសង្ឃឹមថាខ្ញុំនឹងមានកូនតទៅថ្ងៃមុខដកបណា មិនបានរលំដល់សេចក្ដីអត្តរបស់វាដកប:នោះ កូនគេដែលស្រឡាញ់រូបកូនក្រមុំយ៉ាងណា កាលបើគេវិញថ្មីឲ្យក៏ឃើញថារូបថ្មីនោះល្អជាង

ចាស់យាន់ណាមិញ មនុស្សលោកមិនគោរពខ្លាះកាលយល់អារម្មណ៍ ដែលជាទីគាប់ចិត្តហើយដែលមិនសម្រេចដូចសេចក្តីប្រាថ្នា គួរតែពេញចិត្តផងជាតក់ស្លន់ខ្លួនយ៉ាងនោះដែរ ។

ដល់លោកគ្រូបែរមុខមើលលើតុឃើញមានសំបុត្រឲ្យពរស័ព្ទសាធុការមួយសន្លឹក ការ៉ូងជាក់ឈ្មោះណុជនេត្រនារី, លោកគ្រូដញ្ជឹងគិតថាហេតុដូចម្ដេចបានជាអាចារ្យមិនទុកដាក់សំបុត្រនេះនៅក្នុងស្រោមបួល ឬជាមួយនឹងសំបុត្រឯទៀតៗ បែបដូចជាត្រងើយកន្ដើយ មិនរវល់នឹងសិស្សសោះ ហើយសិស្សក៏ត្រម៉ុវប៉ុកងស្រឡាំងកាំង នេះបានជាចិត្តអាចារ្យមែន ។

លុះដល់ពេលប៉ មានភ្ញៀវមកជុំទាំងស្រុកាចារ្យបុរសក៏មកដែរ អ្នកទាំងអស់គ្នាបរិភោគអាហារនៅទីនោះតណ្ហា លាសេចក្ដីសប្បាយរីករាយ ។ ប្រហែលម៉ោង ៩ ណុជនេត្រនារីក៏មកដល់ លោកគ្រូមិនចង់ឲ្យរាកអញ្ជ្រាស្រីយរបស់គាត់ ក៏ថយទៅអង្គុយមុខពីយ៉ាណូ ទើបប្រារព្ធនឹងលេងភ្លេង ដល់ភ្លេងនោះពីរោះស្រទន់ស្រងាត់ អ្នកឯទៀតក៏បានអង្វរលោកគ្រូឲ្យច្រៀងផ្សំឡើង ទើបលោកគ្រូព្រមទំនុកឡើងថា៖

« ឱ! ឱ! គួរស្ដាយមិនគួរធ្លោយសោះ
ទៅសែនអាឡោះកាលយើងពាន់ពេក!
លុះនឹកដើមដល់ពេលនាគសង្វេគ
បានឲ្យរៀមផ្ដេកក្បាលលើដៃស្រី ។

"ឥឡូវបែរប្រែតែទឹកមុខក្រាម
ឲ្យរៀមទឹមតាមខ្ញុំតាល់សេចក្តី
តហេតុតែកម្មប្រចាំថ្មី ។
ទើបកល្យាណីស្អប់ខ្ពើមបែរខ្នង ។

"ផម្កាបុប្ផាតែងតែរោយរោយ
ខាត់ខ្លាយឃ្លាតឆ្ងាយចាកបញ្ញើទង
តែមានក្រពុំហោសឡើងបំព្រង
តែល្អតទូងគួរឲ្យស្នេហា ។

"ថ្ងៃនេះមានចក្រពាររវេលាល្អ
គួរយើងស្មោះសរដល់លោកទេព្តា
ដែលយាងចុះមកបីបាច់រក្សា
ពស្តុកសីមាឲ្យបានក្សេមក្សាន្ត ។

"អារម្មណ៍ចាស់នោះយើងលើកចោលចេញ
បណ្តេញកុំឲ្យវ៉ល់កុលុយបាន
ព្រោះយើងនៅក្មេងតោងតែគិតការ
រចឲ្យកុំផានកុំស្តាយចាស់អើយ" ។

កាលបើសូរក្មេងលេងទ្រហឹងហើយ សោភ័ក្ត្រក៏ដេងក្នែតមើល មុខណាផនគ្រូនារី តែនាងបែបដូចជាព្រងើយមិនស្តាប់ចំរៀងសោភ័ក្ត្រ

បែរទៅនិយាយលេងជាមួយនឹងក្មេងៗទៅវិញ   អាចារ្យក៏ថ្លែងសេចក្តីសង្កេតឡើងថា៖

“មើលប្អូន ចំរៀងសោកស្ត្រីពីរោះទេ” ។

“ចា៎ះ ដឹងអី ខ្ញុំមិនបានស្តាប់ផង មើលទៅប្រហែលជាមិនពីរោះទេ”

“អត់ទោសអ្នក” សោកស្ត្រីឆ្លើយកាត់ឡើង កាលពីប៉ុន្មានខែមុននោះ នាពេលរាត្រីមួយ អស់លោកអ្នកអញ្ជើញមកទីនេះបានឲ្យខ្ញុំលេងភ្លេង ខ្ញុំក៏បំពេញតន្ត្រីស័យអស់លោក ដោយសំដែងសេចក្តីកំសត់របស់ខ្ញុំ ហើយពេលនោះអ្នកក៏បាននៅក្នុងជំនុំអ្នកស្តាប់ផង ហើយអ្នកបានសរសើរស្នាដៃរបស់ខ្ញុំ ព្រមទាំងសូមខ្ញុំសៀវភៅភ្លេងរបស់ខ្ញុំផង ឬមួយខ្ញុំភាន់ច្រឡំទេដឹង? ឮពាក្យលេបខាយដូច្នោះហើយ ណាដេក្រិកបិទភ្នែកផ្ងារក្បាលយ៉ាងខ្ពស់ទៅម្ខាងទៅ សំដែងកិរិយាឲ្យដឹងថា “នាងមិនចូលចិត្តនឹងសោកស្ត្រីដល់បន្តិចបន្តួចសោះឡើយ   សោកស្ត្រីក៏មិនធ្វើដឹងនាំឲ្យនាងទៀតសើចគឹលឡើង” ។

កាលលៀងតែជាមួយនឹងនំនែករួចហើយ   បណ្តាញាតិមិត្តទាំងនោះ ក៏ជូនពរសព្វសាធុការដល់គ្នាទៅវិញទៅមកទ្រហឹងអឺងកង សឹងជាពាក្យដ៏ពីរោះផ្អែមល្ហែមគួរស្តាប់ចាប់ត្រចៀក; នៅទីបំផុត បណ្តាភ្ញៀវទាំងអស់បានជូនពរដល់អាចារ្យជាម្ចាស់ផ្ទះ   រួចលាគ្នាត្រឡប់ទៅកាន់គេហដ្ឋានរៀងៗខ្លួន ។

(មានត)

# ឯកសហស្សរាត្រី

ឬមួយពាន់មួយយប់ ( ជារឿងអារ៉ាប់ )

## ភាគទី ១១

# រឿងផាងស្ប៊ីត

( តមក )

កាលនិយាយពាក្យនេះរួចហើយ ស្រីទេពអប្សរនោះកៀកទបព ខ្ញុំម្ចាស់ខ្ទាប់ដោយដៃម្ខាង ហើយដៃម្ខាងទៀតកាន់មេក្តៃហ៊ាំងពីរ រួចក៏នាំហោះហើរទៅដល់ផ្ទះខ្ញុំម្ចាស់ឯក្រុងបាកដាទឯណោះ, ខ្ញុំម្ចាស់បានឃើញទ្រព្យសម្បត្តិទាំងអស់ដែលផ្ទុកក្នុងសំពៅនោះ នៅពេញក្នុងឃ្លាំងជាស្រេច ដូចពាក្យដែលនាងបានប្រាប់ខ្ញុំនោះមែន ៗ មុននឹងលាខ្ញុំម្ចាស់ទៅ ស្រីអប្សរបានប្រគល់មេក្តៃទាំងពីរមកឲ្យហើយនិយាយផ្តាំថា "ការដែលដាក់ទោសប្អូនទាំងពីរនាក់ឲ្យក្លាយទៅជាមេក្តៃហ៊ាំងនេះ ក៏នៅមិនទាន់ធួននៅឡើយទេ ខ្ញុំត្រូវដាក់កំហិតឲ្យនាងវាយមួយរយរំពាត់ម្នាក់ៗ ថែមទៀតរាល់ៗ យប់ ដើម្បីផ្តាញ់ផ្តាលនូវទោសកំហុសដែលធ្វើខុសលើនាង ហើយនឹងលើព្រះអគ្គម្ចាស់នោះ ៗ ខ្ញុំម្ចាស់បានធ្វើសេចក្តីប្តេជ្ញាជាមួយនឹងនាងទេពអប្សរដោយដាច់ខាតថា នឹងទទួលធ្វើតាមបង្គាប់របស់នាង ៗ

តាំងពីពេលនោះមក ខ្ញុំម្ចាស់តែងធ្វើបាបរាល់ៗ យប់ ប៉ុន្តែធ្វើទាំងស្តាយដូចជាទ្រង់បានទតឃើញជាបន្ទាល់ស្រាប់ ៗ ពេលដែលត្រូ

ទារុណកម្ម (អំពើកាចសាហាវ, អំពើអាក្រក់) យ៉ាងនេះម្ដងៗ នោះ ខ្ញុំម្ចាស់ខឹងខ្ញាល់ចិត្តខ្លាំងណាស់ ធ្វើទៅទាំងបង្ខំទាំងពុញ្ញត្រាន់ជាទីបំផុត តែមិនដឹងគេចវៀសដូចម្ដេចពុំបាន ព្រោះជាកិច្ចត្រូវតែធ្វើដោយជាប់ខាត តាមកំហិតរបស់នាងទេពអប្សរ; កាលដែលបានវាយរួចហើយ ខ្ញុំម្ចាស់យំទ្រហោឡូលឱបថើបនោះ ដើម្បីសំដែងទឹកចិត្តឲ្យឃើញជាបន្ទាល់នៃសេចក្ដីឈឺណាស់អាសូរពិតៗ ។ រឿងរបស់ខ្ញុំម្ចាស់ចប់ត្រឹមនេះហើយ ប្រសិនបើមានរឿងអ្វីខ្លះទៀត ជាកិច្ចធុរៈទាក់ទងមកលើរូបខ្ញុំម្ចាស់ដែលទ្រង់សព្វព្រះទ័យចង់ជ្រាបនោះ ត្រូវសួរនាងអាមីនដែលនឹងដំណាលរឿងខ្លួនក្រាបទូលទ្រង់ ក្នុងកាលឥឡូវនេះ ។

លុះទ្រង់ព្រះសណ្ដាប់រឿងនាងសូបីត ដោយសេចក្ដីអស្ចារ្យយ៉ាងនេះរួចហើយ កាលហ្នឹងទ្រង់បង្គាប់អគ្គមហាឲ្យសុំអញ្ជើញអាមីន ឲ្យនិយាយរឿងខ្លួនដែលមានសំឡាកក្រិតក្រៀវត្រង់ទ្រូងនោះ តើដោយហេតុអ្វី ។ អាមីនបានទទួលប្រតិបត្តិតាម ហើយក៏ចាប់ផ្ដើមថ្លែងរឿងរបស់ខ្លួនដូចតទៅនេះ ។

## រឿងនាងអាមីន

នាងអាមីន ក្រាបទូលថា បពិត្រព្រះសម្មតិទេព រឿងរ៉ាវនាងដើមទ្រង់បានជ្រាបសព្វគ្រប់តាមសេចក្ដី ដែលនាងសូបីតបងស្រីខ្ញុំម្ចាស់ទើបនឹងដំណាលក្រាបទូលអម្បាញ់មិញនេះហើយ ខ្ញុំម្ចាស់មិនបាច់

និយាយបន្ថែមទៀតនាំឲ្យខ្លាន់ផែល ៗ ទេ នឹងតាប់និយាយត្រឹមថាយខ្ញុំម្ចាស់ផែលនៅមេម៉ាយហើយទិញផ្ទះមួយនៅជាប់ដោយខ្សែក; គាត់បានយកទ្រព្យសម្បត្តិជាគ្រឿមតិកផែលឪពុកខ្ញុំម្ចាស់ទុកឲ្យនោះ មកតាក់តែងរៀបចំឲ្យខ្ញុំម្ចាស់មានប្តីជាអ្នកមានគោត្រសម្បូរ ស្តុកស្តម្ភក្នុងក្រុងនេះ ។

ឆ្នាំដំបូងផែលខ្ញុំម្ចាស់ការហើយនោះ មិនទាន់ទាំងកន្លងផុតទៅផង ប្តីខ្ញុំម្ចាស់ទទួលអនិច្ចកម្មទៅ ខ្ញុំម្ចាស់ក៏នៅមេម៉ាយហើយទទួលភារៈជាម្ចាស់ផ្ទះ បីបាច់រក្សាទ្រព្យសម្បត្តិរបស់ប្តីយ៉ាងច្រើនដល់ទៅប្រាំ-បួនម៉ឺនកហាបណៈ ។ គ្រឿមតិចប៉ុណ្ណោះឯង ល្មមចិញ្ចឹមជីវិតបានបរិបូណ៌ដោយត្រជាក់ត្រជំ ។ តាំងពីទន្ទឹងខាតប្តីខ្ញុំម្ចាស់រាប់ ២ ខែ ដំបូងកន្លងផុតទៅហើយ ខ្ញុំម្ចាស់ក៏កាត់ខោអាវថ្មី ១០ ប្រដាប់មានពណ៌ផ្សេង ៗ គ្នាហើយមានលំអយ៉ាងស្រស់ ក្នុងមួយប្រដាប់ ៗ ថ្លៃមួយពាន់កហាបណៈ; ខ្ញុំម្ចាស់បានតាប់ស្លៀកពាក់ខោអាវទាំងនោះក្នុងពេលជាប់គ្នា ។

ក្នុងសម័យថ្ងៃមួយ ខ្ញុំម្ចាស់នៅតែម្នាក់ឯងកំពុងធ្វើកិច្ចការក្នុងផ្ទះ ស្រាប់តែមានគេមកប្រាប់ថា ស្រីម្នាក់ត្រូវការជួបនឹងខ្ញុំម្ចាស់ ។ ក៏បានយល់ព្រមឲ្យស្រីនោះចូលមកក្នុង; នាងនោះជាស្រីចាស់អាយុច្រើនណាស់ទៅហើយ ចូលមកសំពះខ្ញុំម្ចាស់ក្រាបកប្រទៅនឹងដី ហើយនិយាយដោយសំដីទន់ក្លន់ថា "ឱអ្នកស្រីអើយ សូមមេត្តាអត់ទោស

សន្តោសៈប្រោសប្រាណដល់ខ្ញុំឲ្យបាន  សូមនាងកុំប្រកែប្រកាន់ចាប់ទោសខ្ញុំសំណើថា  ខ្ញុំចូលមកធ្វើអ្វីទ្រុករុកក្នុងផ្ទះឡើយ  ខ្ញុំមានសេចក្ដីសង្ឃឹមទុកចិត្តថានាងជាអ្នកមានធម៌សប្បុរសពិតៗ  បានជាខ្ញុំហ៊ានចូលមកសូមនិយាយការនេះ ។ អ្នកស្រី  ខ្ញុំសូមជំរាបប្រសាសន៍អ្នកស្រីជូនសេចក្ដីតទៅនេះគឺ  ខ្ញុំមានកូនស្រីកំព្រាម្នាក់  ហើយបានផ្ដើមរៀបចំធ្វើមង្គលការឲ្យវាក្នុងថ្ងៃនេះឯង,  សោកឯខ្លួនខ្ញុំនេះឥតមានគ្នាសោះ  មានតែពីរនាក់ម្ដាយនិងកូនហើយថែមទាំងជាអ្នកចម្ងាយទៀតផង  ឥតស្គាល់អ្នកឯណាក្នុងក្រុងនេះទេ ។ រឿងនេះហើយដែលនាំឲ្យខ្ញុំបន្ទៀតបន្ទល់ក្រៃប្រមូលលំបាកចិត្ត  មិនដឹងជានឹងទៅសង្ឃឹមពឹងផ្អែកលើអ្នកឯណា ក្រៅពីអ្នកស្រីឡើយ ។ យើងចង់ធ្វើឲ្យបានស្គាល់ត្រកូលជាប្រធានក្នុងក្រុងនេះ ដើម្បីនឹងរៀបចំមង្គលការនោះឲ្យបានរុងរឿងគួរសម  ហើយទាំងខ្លួនយើងក៏នឹងបានទៅជាញាតិសាលោហិត  ជិតដិតនឹងអ្នកទាំងពួងក្នុងក្រុងនេះផង និងបានទៅជាអ្នកមានកេរ្តិ៍ឈ្មោះល្អ  ល្មមឲ្យគេទុកចិត្តយើងបានផង ។ អ្នកស្រីសប្បុរស, ហេតុនេះ  បើនាងមេត្តាអញ្ជើញទៅជួយជាគ្នាក្នុងមង្គលការនោះបាន  ឈ្មោះថាអ្នកស្រីបានធ្វើឲ្យយើងខ្ពស់មុខដោយសារផង  យើងសូមគុណជាអនេកអនន្តដល់អ្នកស្រី;  ម្យ៉ាងទៀតពួកស្រីៗក្នុងស្រុកនេះ  កាលបើបានឃើញបានដឹងថាមនុស្សជាន់ខ្ពស់ប្រហែលដូចអ្នកស្រី  អញ្ជើញទៅជួយកំដរយើងដោយមិនមានសេចក្ដីមើល-

កាយផ្កាបោះ គេគង់នឹងញញើតយើងខ្លះ ហើយមិនហ៊ានមកជាយូរយើង ជាជាអ្នកទីពឹងទៀយ ។ ប៉ុន្តែខ្ញុំបារម្ភពេកណាស់ ក្រែងលោអ្នកស្រីបែរជាប្រែកកមិនព្រមទទួលតាមពាក្យសូមអញ្ជើញវិញនោះ យើងមុខជាតស់ផ្សរហើយ មិនដឹងជានឹងទៅពឹងផ្អែកលើអ្នកឯណាទៀតទេ" ។

សូរសំដីដែលជូនចាស់និយាយបណ្តើរយំហូរទឹកភ្នែកហោមបណ្តើរ នាំបន្ទន់ចិត្តខ្ញុំម្ចាស់ឲ្យមានសេចក្តីអាណិតអាសូរដល់គាត់ពន់ពេក ទើបខ្ញុំម្ចាស់តបថា "អ្នកតាយ, សូមអ្នកកុំព្រួយ ខ្ញុំនឹងទទួលតាមសេចក្តីពេញចិត្តរបស់អ្នក ។ ប៉ុន្តែត្រូវបន្តុំធាំឲ្យខ្ញុំស្លៀកពាក់តាក់តែងខ្លួនឲ្យស្អាតបាតបន្តិចសិន" ។ ជូនចាស់លុះបានស្តាប់ចម្លើយនេះហើយ ក៏កើតយសប្បាយចិត្តណាស់ ស្រាប់តែស្ទុះមកឱបជើងខ្ញុំម្ចាស់ទាំងពីរហើយងើបក្បាលឡើងនិយាយថា "ឱអ្នកស្រីសប្បុរស! ព្រះជាអម្ចាស់មុខជានឹងប្រទានពរសព្វសាធុការប៉ុន្មានចំរើនដល់អ្នកស្រីពុំខាន ព្រោះអ្នកស្រីបានសង្គ្រោះដល់ចាស់អ្នកកំសត់ទុគ៌ត ហើយព្រះអង្គនឹងបំពេញចិត្តអ្នកស្រីឲ្យពេញបរិបូណ៌ដោយសេចក្តីសុខក្សេមក្សាន្ត តាមបែបដូចជាអ្នកស្រីបានផ្តល់សេចក្តីសុខឲ្យយើងផ្កាបោះដែរ ។ ឯកិច្ចការនោះ អ្នកស្រីមិនបាច់ត្រូវទទួលអញ្ជើញទៅក្នុងពេលឥឡូវនេះទេ ចាំពេលល្ងាចដល់កំណត់ម៉ោង ខ្ញុំនឹងត្រឡប់មកទទួលនាំអ្នកស្រីទៅ; អ្នកស្រី, ណ្ហើយ ខ្ញុំសូមជំរាបលាអ្នកស្រីសិនហើយ ។

ពេលដូនចាស់គ្រាន់តែចេញផុតទៅភ្លាម ខ្ញុំម្ចាស់ក៏យកសំលៀកបំពាក់មួយប្រដាប់ដែលខ្ញុំម្ចាស់ពេញចិត្តមកយូរហើយមកស្លៀកពាក់គាត់តែងខ្លួនអោយមានឥតខ្ចោះពីនៃវម្មតា ចងនាឡិកាដៃ ពាក់ចិញ្ចៀនពាក់ក្រយ៉ៅពេជ្រយ៉ាងល្អផុតលេខមួយ ។ ពេលនោះ ខ្ញុំម្ចាស់មើលតែងនឹងប្រផិតប្រផើយ ថា មុខជានឹងមានហេតុគេទទួលមួយពុំខាន ។

លុះដល់ពេលព្រលប់ លោកយាយចាស់នោះទៅដល់ផ្ទះខ្ញុំម្ចាស់ ដោយមានទឹកមុខញញឹមញញែមចែបសប្បាយណាស់ ។ គាត់បានថើបដៃខ្ញុំម្ចាស់ហើយប្រានិយាយថា "អ្នកស្រីរូបស្រស់, កូនស្រីៗ ជាញាតិសន្ដានខាងកូនប្រុសប្រុសខ្ញុំដែលសុទ្ធតែជាស្រីជាន់ខ្ពស់ គឺក្រើនេះបានមកជួបជុំគ្នាសព្វហើយ អង្គុយរង់ចាំដំណើរអ្នកស្រី; សូមដំណើរប្រែសាសន៍ ឥឡូវនេះដល់ពេលល្មមស្រេចហើយ; ខ្ញុំនឹងនាំអ្នកស្រីទៅ" ។ យើងក៏បានចេញទៅភ្លាម, ដូនចាស់ដើរនាំមុខខ្ញុំម្ចាស់ព្រមទាំងកូនស្រីជាបរិវារខ្ញុំម្ចាស់ជាច្រើននាក់សុទ្ធតែតែងខ្លួនយ៉ាងស្អាតៗ ដើរហែហោមហោមកោមតាមក្រោយខ្ញុំម្ចាស់ទៅ ។ យើងបានឈប់នៅត្រង់ផ្ទះមួយដ៏ធំល្វឹងល្វើយ ដែលទើបនឹងបោសច្រោសទឹកយ៉ាងស្អាត រនៅខាងមុខផ្ទះនោះមានទ្វារធំហើយមានដាក់រនាមចង្កៀងពីខាងលើ, ដោយហេតុពន្លឺគោមនោះឯង ខ្ញុំម្ចាស់មើលទៅឃើញអក្សរទឹកមាសសរសេរនៅត្រង់ស៊ុមទ្វារខាងលើថា "គេហដ្ឋាននៃសេចក្ដីពេញចិត្តចំពោះសេចក្ដី

សព្វព្រាយកើតភ្លើងឆាប់ឆាតិប្ដ" ។ អោយចាស់គោះទ្វារម្ដង ៗ
គេក៏បើកឲ្យក្រាប ។

គេនាំខ្ញុំម្ចាស់ចូលទៅហួតដល់កណ្ដាលផ្ទះ , ទៅដល់បន្ទប់មួយឃើញស្រាប់តែឃើញស្រីក្រមុំម្នាក់ មានរូបឆោមយ៉ាងចំណាប់ភ្នែកប្រដូចគ្មាន ដើរល្បឿនស្ទើរសំដៅមកទទួលកក់ក្ដៅគួរសមនឹងខ្ញុំម្ចាស់ ។ លុះនាងបានចាប់ផ្ដើមបង្គាប់គាប់គួរហើយ ទើបឲ្យខ្ញុំម្ចាស់អង្គុយជិតនាងលើកៅអីវែង ១, ត្រង់កន្លែងនោះមានបល្ល័ង្កមួយធ្វើពីឈើដ៏មានដម្លៃរចិត្រឆ្លាក់ល្អបោយពេជ្រ ៗ ស្រីក្រមុំនោះនិយាយនឹងខ្ញុំម្ចាស់ថា "អូនស្រី, គេអញ្ជើញអ្នកស្រីមកកន្លែងនេះ ដើម្បីបានជាគ្រូកិត្តិមង្គលការ; ប៉ុន្តែមង្គលការនេះប្រឆាំងខុសអំពីមង្គល ដែលអ្នកស្រីបានគិតស្មានទុកមកពីនាយនោះទេ ។ រឿងនោះយ៉ាងនេះវិញទេតើ គឺខ្ញុំមានបងប្រុសម្នាក់កំពុងតែពេញកំឡោះ (កំឡោះហួតជាក់) ហើយជាមនុស្សគ្រប់លក្ខណ៍ជាងជាតិប្រុសទាំងអស់ គាត់មានសេចក្ដីពេញចិត្តចំពោះរូបសម្បត្តិរបស់អ្នកស្រីក្រៃពេក, ព្រោះសំណាងរបស់គាត់ស្រួបតែនឹងអ្នកស្រីទេ (បើអ្នកស្រីឲ្យខ្ញុំសុំក៏បាននូវសំ ...) ហើយគាត់បានប្ដេជ្ញាថាប្រសិនបើអ្នកស្រីមិនករុណាគាត់ទេ មុខជានឹងព្រួយចិត្តអត់បាយក្រហាយទទឹកបែកទ្រូងស្លាប់ពុំខាន ។ អ្នកស្រី, ខ្ញុំហ៊ានធានាអះអាងជំរាបអ្នកស្រីថា រូបសម្បត្តិរបស់បងខ្ញុំនោះពិតជាសមគ្នាណាស់នឹងរូបអ្នកស្រី

គលុម្បូមមិត្រមេត្រីជាស្វាមីភរិយាបាន ,   ខ្ញុំសូមអង្វរអ្នកស្រីកុំឲ្យប្រែចិត្ត ឡើយ   សូមមេត្តាទទួលខ្លួនព្រមធ្វើជាភរិយារបស់បងខ្ញុំហើយ សេចក្តីសង្គ្រោះ”   ។

តាំងពីជួបប្ដីខ្ញុំម្ចាស់ទទួលអនិច្ចកម្មទៅ ខ្ញុំម្ចាស់មិនដែលមានគំនិតគិតគូរបង់បានប្ដីទៀតនៅឡើយទេ,   ប៉ុន្តែពេលនោះនឹងប្រកែកដាច់អហង្ការមិនព្រមទទួលយកមនុស្សវិសេសបែបនេះទៅក៏ហាក់ដូចជាពុំគួរសោះ ខ្ញុំម្ចាស់ក៏យល់ព្រមដោយតុណ្ហីភាព (សេចក្តីស្ងៀម) តាំងដោយភាពអៀនខ្មាសទឹកមុខក្រហមផង ។ នាងក្រមុំនោះគ្រាដែលបានដឹងភាពរបស់ខ្ញុំម្ចាស់ហើយ   ក៏ទះដៃផ្ទួនៗ,   ទ្វារបន្ទប់មួយរបើកភ្លាម   ស្រាប់តែលេចកំលោះម្នាក់   ឫកពារអង់អាច   មានគុណសម្បត្តិខ្ពង់ខ្ពស់ពេញមតក្លែក,   ខ្ញុំម្ចាស់មានសេចក្តីត្រេកអរព្រៃ   ដោយបានទទួលរបស់យ៉ានវិសេសដែលគេបានដោយធម្មយាននេះ   ។   កំលោះនោះមកអង្គុយជិតខ្ញុំម្ចាស់, លុះបាននិយាយរាយសន្ទនាមួយគ្នាហើយ   ខ្ញុំម្ចាស់ក៏បានស្គាល់ជាក់ជា។ គុណសម្បត្តិរបស់គេ   ខ្ពង់ខ្ពស់ថ្លៃថ្លាជាងសំដីដែលបងស្រីបាននិយាយប្រាប់ខ្ញុំម្ចាស់ហើយទៀត   ។

កាលបានឃើញយើងទាំងពីរនាក់រួសរាយសប្បាយចិត្តជាមួយគ្នាហើយ   នាងក្រមុំក៏ទះដៃផ្ទួនៗ   ម្ដងទៀតជាគំរប់ពីរដង   លោតែលេចអ្នកមហាម្នាក់ចូលមកដល់ភ្លាមជាមួយនឹងសាក្សី ៤ នាក់ផង   ហើយក៏តាំង

ស្ត្រីសេចក្តីសំបុត្រសញ្ញានៃអាពាហ៍ពិពាហ៍ រួចចុះហត្ថលេខាក្នុង សំបុត្រនោះព្រមទាំងឲ្យសាក្សី ៤ នាក់ដែលចូលមកជាមួយនោះ ចុះហត្ថ-លេខាជាប់ផ្ទាល់ជួយអឹងឡៃថែមទៀតផង ។ រឿងដ៏សំខាន់ដែលប្តីថ្មី របស់ខ្ញុំម្ចាស់បញ្ញត្តដោយដាច់ខាតចំពោះរូបខ្ញុំម្ចាស់នោះគឺ គាត់ហាមខ្ញុំម្ចាស់មិនឲ្យមើលមិនឲ្យនិយាយនឹងជាតិប្រុសណាមួយក្រៅពីគាត់ឡើយ ហើយគាត់បានបង្ហាញដាក់កំហិតថា លុះត្រាតែខ្ញុំម្ចាស់ប្រព្រឹត្តតាម បញ្ញត្តិនេះ ទើបគាត់ស្រឡាញ់ខ្ញុំម្ចាស់ ។ អាពាហ៍ពិពាហ៍របស់យើង ចប់ស្រេចត្រឹមប៉ុណ្ណោះឯង ។ ដើមហេតុដំបូងនៃអាពាហ៍ពិពាហ៍នោះ គេគ្រាន់តែអញ្ជើញខ្ញុំម្ចាស់ទៅដើម្បីបានជាគ្នាតែប៉ុណ្ណោះ ដូចសេចក្តី ដែលបានរៀបរាប់រួចមកហើយ ។

ពេលនោះហើយបានចំនួនមួយខែ ខ្ញុំម្ចាស់ត្រូវការបង់បានសំពត់មកប្រើប្រាស់ខ្លះទៀត ក៏សូមអនុញ្ញាតច្បាប់ពីស្វាមី ដើម្បីទៅរកទិញរបស់នោះឯង ។ ស្វាមីបានយល់ព្រមបើកឲ្យទៅតាមបំណង, ខ្ញុំម្ចាស់យកជូនតាស់ដែលបាននិយាយហើយនោះ ព្រមទាំងស្រីបំរើពីរនាក់ទៀតឲ្យជូនទៅផង ។ លុះទៅដល់ផ្សារ ជូនតាស់និយាយនឹងខ្ញុំម្ចាស់ថា "អ្នកស្រី, បើអ្នកស្រីត្រូវការសំពត់ព្រែ ខ្ញុំនឹងនាំអ្នកស្រីទៅឯផ្ទះពាណិជម្នាក់ ដែលខ្ញុំធ្លាប់ស្គាល់នៅទីផ្សារនេះ ខ្ញុំហ៊ានធានាថា ពេលបើអ្នកស្រីអញ្ជើញទៅផ្ទះនោះ គឺបានការស្របតែម្តង មិនចាំបាច់អញ្ជើញ

ទៅផ្ទះឯទៀត ៗ នាំឲ្យនឿយហត់ទេ ព្រោះផ្ទះពាណិជនោះមានសំពត់គប់បែបទាំងអស់ "ស្រេចតែនឹងរើសតាមចិត្ត" ។ ខ្ញុំម្ចាស់ក៏យល់ព្រមបណ្ដោយតាមពាក្យគាត់ហើយយើងចូលទៅក្នុងផ្ទះពាណិជនោះ បានឃើញថាជាអគ្គស្ថានសម្បូរសម្បែង; ខ្ញុំម្ចាស់អង្គុយហើយបានបង្គាប់ឲ្យជូនចាស់និយាយសុំឲ្យអ្នកជំនួញនោះបង្ហាញសំពត់ព្រែដែលល្អជាងគេ ។ ឯជូនចាស់បានឲ្យខ្ញុំម្ចាស់និយាយសួរតទល់មាត់គ្នានឹងពាណិជនោះឯង ប៉ុន្តែខ្ញុំម្ចាស់ប្រាប់គាត់ថា "កុងស៊ីបុត្រសញ្ញានៃការពាណ៍ពិពាហ៍របស់ខ្ញុំហាមមិនឲ្យខ្ញុំនិយាយតទល់មាត់ជាមួយនឹងប្រុសដទៃក្រៅពីប្ដីខ្ញុំទេ ហេតុនេះ ខ្ញុំមិនត្រូវប្រព្រឹត្តកន្លងច្បាប់នោះដោយដាច់ខាត" ។

ពាណិជយកសំពត់ព្រែច្រើនបែបមកបង្ហាញខ្ញុំម្ចាស់ ។ ពិនិត្យមើលហើយក៏ពេញចិត្តនឹងសំពត់ព្រែមួយបែបដែលល្អជាងគេ ទើបឲ្យជូនចាស់និយាយសួរថ្លៃសំពត់នោះ ។ ពាណិជឆ្លើយតបមកជូនចាស់វិញថា "ទេ ; ខ្ញុំមិនត្រូវការលក់ដូរយកថ្លៃជាមាសប្រាក់ឡើយ សុំឲ្យតែនាងនេះព្រមឲ្យខ្ញុំថើបថ្ពាល់តែមួយខ្សឹតប៉ុណ្ណោះ ហើយយកសំពត់នេះទៅចុះ" ។ ខ្ញុំម្ចាស់បង្គាប់ជូនចាស់ឲ្យប្រាប់គេថា "ខ្ញុំយល់ព្រមពុំបានទេ ព្រោះការដែលធ្វើដូច្នេះជាអំពើដ៏អាក្រក់ហ៊ានល្មើសពានខុសច្បាប់ទាំងស្រុង" ។ ជូនចាស់បែរជាមិនទទួលស្ដាប់ពាក្យខ្ញុំម្ចាស់សោះ ត្រឡប់ជាអែបចូលដៃខាងពាណិជនោះទៅវិញ ហើយនាំគ្នានិយាយ

បញ្ចុះបញ្ចូលខ្ញុំម្ចាស់ថា "ការដែលពាណិជ្ជនិយាយសុំថើបនេះមិនមែន
ជាកិច្ចធ្ងន់នាំឲ្យបង់ខាតអ្វីទេ គេមានប្រើយើងឲ្យទៅសែងលីវ៉ែតពុំគ្រី
សព្វបើគ្រាន់តែផ្ទៀងហុចថ្ពាល់ឲ្យគេថើបតែមួយទៀតប៉ុណ្ណោះហើយយើង
បានសំពត់ទេ គ្មានដាច់ខាតថ្លៃថ្នូរអ្វីផង, យ៉ាងនេះមិនគ្រាន់បើ? បើតាម
យោបល់ខ្ញុំថាគួរតែប្រថុយទៅកុំចាំបាច់ឲ្យខាតលុយយើង" ។ ខ្ញុំម្ចាស់
ក៏ពេញស្តាប់ចិត្តស្តុកយល់ព្រមតាមសំដីគាត់ ព្រោះពង់បានសំពត់នោះ
ណាស់ ។ ដូចជាស៊ូនងស្រីបរើ ឈរបាំងពីខាងមុខខ្ញុំម្ចាស់ ដើម្បី
កុំឲ្យអ្នកផងមើលឃើញ ។ នៅវេលានោះពាណិជ្ជមិនថើបខ្ញុំម្ចាស់ទេ
តែត្រឡប់ជាខាំថ្ពាល់ខ្ញុំម្ចាស់ទាល់តែដាច់ចេញឈាមទៅវិញ ។ ខ្ញុំម្ចាស់
មានសេចក្តីស្តុតខ្មាសញាប់ញ័រនឹងសេចក្តីឈឺចាប់ជាខ្លាំង ងើងងោងវិល
មុខទាល់តែដួលសន្លប់បាត់ស្មារតីហើយដេកស្តូកស្តឹងអស់ពេលមួយស្រ-
បក់ធំ, ពេលនោះទុកជាឱកាសល្អបណ្តោយឲ្យពាណិជ្ជនោះបិទទ្វារផ្ទះ
ហើយគេចខ្លួនរត់បាត់ទៅ ។ កាលខ្ញុំម្ចាស់មានស្មារតីឡើងវិញ ក៏បាន
ដឹងថាថ្ពាល់ខ្លួនឯងប្រឡាក់ជោគទៅដោយឈាម ។ ដូចជាស៊ូនងស្រី
បរើ នាំគ្នាយកសំពត់មកចងរុំគ្របមុខឲ្យខ្ញុំម្ចាស់ ដើម្បីកុំឲ្យអ្នកផង
ដែលផ្តើលគោរពមកមើលដឹងការនោះច្បាស់ឡើយ ឲ្យគេគ្រាន់តែដឹង
ជាតឹងជាខ្យល់ចាប់បន្តិចបន្តួចប៉ុណ្ណោះទៅវិញ ។

ដូចតាសំមានសេចក្ដីភិតភ័យខ្លាំងណាស់ ទៀនស្វាយបំបូរមាត់ គាត់ខឹកគួចចិត្តរៀបរងសារីរក្ដៅក្រហាយស្ដាយក្រោយជាទីបំផុត ព្រោះតែគ្រោះថ្នាក់នេះឯង ហើយគាត់និយាយលួងលោមខ្ញុំម្ចាស់ថា "អ្នកស្រីទៅហ្វាយ, សូមអ្នកស្រីមេត្ដាអភ័យទោសដល់ខ្ញុំ ព្រោះខ្ញុំជាអ្នកនាំគាត់ឲ្យអ្នកស្រីទទួលគ្រោះថ្នាក់នេះ; បានជាខ្ញុំនាំអ្នកស្រីឲ្យអញ្ជើញទៅផ្ទះពាណិជនោះ ព្រោះភ្ជាប់នៅស្រុកជាមួយនឹងខ្ញុំហើយខ្ញុំគិតដឹងជាត់សាចការត្រូវជួជាតិយ៉ាងនេះសោះ ប៉ុន្ដែសូមអ្នកស្រីកុំព្រួយ យើងខំត្រឡប់ទៅផ្ទះវិញឥឡូវនេះ ខ្ញុំនឹងយកថ្នាំ ១ មុខយ៉ាងពូកែស័ក្ដិសិទ្ធិមកលាបប្ញស្សនេះឲ្យសះជាស្រឡះ ក្នុងរវាង ៣ ថ្ងៃហើយកុំឲ្យមានស្នាមសំឡាកបន្ដិចបន្តួចឡើយ" ។ ខ្ញុំម្ចាស់នៅអស់កំឡាំងជេងជោង ដើរបានតាំងទទ្រេតទទ្រោត ប៉ុន្ដែខំប្រឹងទប់ខ្លួនដើរទាល់តែដល់ផ្ទះ; លុះបូបេទៅដល់ក្នុងបន្ទប់ ខ្ញុំម្ចាស់វិលមុខស្ទើរស្ទួបប៉ាក់ស្មារតីម្ដងទៀត ដូនតាសំយកថ្នាំនោះមកលាបឲ្យ ទើបបានដឹងខ្លួនឡើងវិញ ហើយខ្ញុំម្ចាស់ទទួលព្រះពរទានដំណេកទទូរលើគ្រែ ។

ដល់ពេលយប់បន្ដិច ប្ដីខ្ញុំម្ចាស់មកដល់; គាត់បានឃើញខ្ញុំម្ចាស់ទទួលព្រះពរទានដំណេកទទូរដិតតាំងក្បាលដូច្នោះ គាត់ស្រែកសួរមកថា មានរោគឈឺចាប់ដូចម្ដេចបានជាដេកទទូរ ។ ខ្ញុំម្ចាស់ជំរាបគាត់ថា អត់មានរោគអីធ្ងន់ទេ គ្រាន់តែឈឺក្បាលបន្ដិចបន្តួច; ខ្ញុំម្ចាស់ស្មានថា

គាត់គ្រាន់តែសួរពីចម្ងាយ ហើយគាត់មិនមកពិនិត្យមើលជិតទេ ស្រាប់
តែអ្នកបាទនោះទុំដទៀតនាងចំកូបួលមកពិនិត្យមើលមុខខ្ញុំម្ចាស់ កាល
ឃើញស្នាមរបួសត្រង់ថ្ពាល់ដូច្នោះក៏សួរក្លាមថា ហេតុដូចម្ដេចបានជាមាន
របួសដូច្នេះ? ៗ សូម្បីខ្លួនខ្ញុំម្ចាស់មិនមែនជាមនុស្សមានទោសដល់ថ្នាក់
ត្រូវក្រដូទេ ប៉ុន្តែខ្ញុំម្ចាស់មិនអាចនឹងឆ្លើយសូមទោសប្ដីតាមត្រង់បានឡើយ
បើខ្ញុំម្ចាស់ឆ្លើយប្រាប់តាមសេចក្ដីពិតហើយ សូមលែងគួរឲ្យគាត់អត់ទោស
ដល់ខ្ញុំម្ចាស់ទៅ ពីព្រោះដូចជានឹងនាំឲ្យខូចដល់កិរិយាមារយាទជាតិជាស្រ្តី
ទើបខ្ញុំម្ចាស់ឆ្លើយដោះសាថា "រឿងនេះមកពីខ្ញុំទៅរកទិញសំពត់ក្រែង
ផ្សារ ដែលអ្នកជាស្វាមីក៏បានដឹងឮ ហើយអនុញ្ញាតប្រាប់ឲ្យខ្ញុំទៅនោះឯង
គឺមានអ្នកស៊ីឈ្នួលម្នាក់ លើកសប្រជែងប្រណាំងដើរប្រៀបតមតជិតខ្ញុំ
ត្រង់ផ្លូវយ៉ាងចង្អៀត ហើយកន្ទុយ១សនោះក៏វាត់មកប៉ះត្រូវថ្ពាល់ខ្ញុំមុត
មានស្នាមរបួសដូច្នេះ ប៉ុន្តែការនេះគ្រាន់តែបន្តិចបន្តួចមិនជាធ្ងន់ធ្ងរទេ ៗ

ចម្លើយដោះសានេះប៉ុនគេយកភ្លើងទៅសោ ទៅដុតប្ដីខ្ញុំម្ចាស់នៅវិញ
គាត់លោតឹងប្រទេទ្លក់ឡើង និយាយនឹងខ្ញុំម្ចាស់ដោយសំឡេងយ៉ាងតឹង
បំពង់កថា "រឿងនេះអញនានយកទោសមិនបានទេ ចាំស្អែកអញនឹង
ធ្វើសំបុត្រទៅប្ដឹងលោកនាយកកងក្រវែល ឲ្យចាប់ពួកអាចោរស៊ីឈ្នួល
គេឲ្យត្រីខ្មែរជួជាតិតាំងអស់នោះ យកទៅចងព្យួរសម្លាប់ចោលឲ្យអស់គូឲ្យ
សល់ ៗ ខ្ញុំម្ចាស់និតកីយណាស់ ព្រោះការបើធ្វើដូច្នេះ ខ្លួនខ្ញុំម្ចាស់នឹង

ទៅជាមេតាបណ្ដាលឲ្យមនុស្សប្រែនគ្នា ដែលផលទោសនោះនោះស្លាប់អន្តរាយពីព្រោះតែខ្លួនឯង ទើបខ្ញុំម្ចាស់និយាយថា "បពិត្រស្វាមីអើយ ការដែលៈក្ដីដោយអយុត្តិធម៌យ៉ាងនេះ ខ្ញុំមិនពេញចិត្តទេ សូមអ្នកកុំប្រព្រឹត្តអំពើខុសច្បាប់យ៉ាងនេះ ប្រសិនបើអ្នកនាំសេចក្ដីបន្តើកឲ្យមានគ្រោះថ្នាក់ដូច្នោះមែន ខ្លួនខ្ញុំនឹងទៅជាមនុស្សមានទោសធ្ងន់ណាស់ ព្រោះខ្ញុំជាមេតាបណ្ដាល" ។ គាត់គំហកសួរទៀតថា —"ម្រោរកា-ឡកណ្ណី! ហានឯងប្រាប់អញឲ្យត្រង់មករបួសនេះតើមកពីហេតុអ្វី ?" ។

ខ្ញុំម្ចាស់ឆ្លើយភ្លាមថា "មកអំពីអ្នកលក់អំបោសម្នាក់ វាដើរលាមកពីក្រោយខ្ញុំហើយវាបំបត់ក្បាលលាឲ្យត្រឡប់ពីខាងឆ្វាង ដោយមិនបានដាគិតមើល លានោះក៏ដាក់ថយមកប៉ះទង្គិចត្រូវខ្ញុំយ៉ាងខ្លាំង ខ្ញុំដួលផ្កាប់មុខប៉ះថ្ពាល់ត្រូវនឹងអំបែងកែវ ទើបមុខរបេះមានស្នាមដូច្នេះ" ។ ពេលនោះប្ដីខ្ញុំម្ចាស់កាន់តែខឹងឡើងទៀតហើយគាត់បញ្ចេញសំដីថា "អើបើដូច្នោះមែន ក្រែងតែស្អែក កុំឲ្យមានថ្ងៃរះទើបរួចខ្លួន បើស្អែកនេះមានថ្ងៃរះឡើងនោះ មុខជាអញនឹងទៅប្ដឹងលោកអគ្គមហាសេនា យ៉ាហ្វារ អំពីបទល្មើសឈ្នានពាននេះឯងឲ្យលោកកាត់ទោសសម្រាប់ពួកអាដែលឈ្មួញអំបោសទាំងនោះហោលឲ្យអស់" ។ ខ្ញុំម្ចាស់ប្រឹងទៀតឆ្លើយយ៉ាងប្រញាប់ថា "ទូលស្វាមីម្ចាស់ខ្ញុំអើយ ខ្ញុំសូមយកព្រះមកជាទីតាំង សូមអកមេត្តាកត់ទោសផលពួកឈ្មួញអំបោសទាំងអស់នោះឲ្យខាន ព្រោះគេមិនមែន

ជាមនុស្សមានទោសទេ" ។ គាត់ស្រែកសន្ធាប់មងទៀតថា "ឲ្យអញជឿសំដីហែងឯងដូចម្តេចបាន ម្តងថាដូច្នេះ ម្តងថាដូច្នោះ; ម្តងនេះប្តូរហែងប្រាប់ឲ្យត្រង់ អញពង់ដឹងសំដីពិតរបស់ហែងឯងហើយជាប់ខាត" ។ ខ្ញុំម្ចាស់ឆ្លើយដោះសារទៅទៀតថា "បពិត្រអ្នកស្វាមីជាម្ចាស់ មកពីខ្ញុំត្រូវខ្យល់បាប់វិលមុខហើយដួលទន្ទិចប្លាស់ទៅនឹងដី ទើបមានរបួសដូច្នេះឯង" ។

លុះស្តាប់ចម្លើយខាងក្រោយបំផុតនេះហើយ ប្តីខ្ញុំម្ចាស់ទ្រាំអត់ធ្មត់ពុំបាន គាត់ខឹងផ្ទុះឡើងពុះកញ្ជ្រោលខ្លាំងណាស់ ទើបស្រែកគំរាមដេរថា "មេចោរផ្តេកផ្តួល! អញស្តាប់ពាក្យកុហករបស់ឯងច្រើនយូរណាស់ហើយ អញនឹងទ្រាំស្តាប់តទៅទៀតពុំបានទេ" ។ គាត់ថាតែប៉ុណ្ណោះហើយក៏ទះដៃដូង១ស្រាប់តែឃើញមនុស្សប៉ុន្មាន ៣ នាក់ចូលមកដល់ភ្លាម, គាត់គាំងបង្គាប់ភ្លាមថា "ចូរនាំគ្នាចាប់អ្នកស្រីទំលាក់ពីលើគ្រែចេញហើយយកវាទៅទាញសន្ធឹងឧណ្ហាលលៃងផ្ទះឲ្យតាប់១" ។ បាវទាំងនោះក៏ទទួលធ្វើតាមបង្គាប់គាត់, ម្នាក់ចាប់ក្បាលខ្ញុំម្ចាស់, ម្នាក់ចាប់ជើងទាញពីរវៃសងទំលាក់ពីលើគ្រែមក ហើយគាត់ប្រើម្នាក់ទៀតឲ្យទៅយកដាវ, លុះបាវនោះយកដាវមកដល់ហើយ ទើបគាត់ស្រែកបង្គាប់ថា "ទៅ, កាប់វាជាពីរកំណាត់ហើយយកទៅបោះចោលក្នុងទន្លេ,

ចិត្រ[១] ឲ្យត្រាក់ស៊ីទៅ ទុកវាឲ្យរស់នៅមិនបានទេ មេចោរគោឲ្យធណ្ណីនេះ; នេះហើយជាសេចក្តីផ្ទា គឺអញត្រូវធ្វើដល់មនុស្សដែលអញស្រឡាញ់ អស់ពីពោះ ហើយវាបានគំនិតកាក្រក់ធ្វើឲ្យអញខូចចិត្ត" ។ គាត់ ឃើញបំរើដែលកាន់ដាវនោះ មិនទទួលធ្វើតាមបង្គាប់ដោយប្រញាប់ ប្រញាល់ ទើបគាត់គំហកទៀតថា "វ៉ៃទៅ, អ្នកណាបញ្ឈប់អាឯង? អាឯងចាំអីទៀត?" ។ គ្រានោះបាវនិយាយទៅនឹងខ្ញុំម្ចាស់ថា "អ្នកស្រី, នៅពេលក្រោយបំផុតនេះ អ្នកស្រីគួរនឹកអំពើណា បាបធម៌ខ្លោចចិត្តណាស់ នឹងជីវិតរបស់ខ្លួន សូមអ្នកស្រីពិចារណាមើលឲ្យសព្វគ្រប់ ពេលមុន នឹងស្លាប់នេះបើមានកិច្ចការអ្វីត្រូវនិយាយ សូមអ្នកស្រីនិយាយឲ្យហើយ ទៅ" ។

ខ្ញុំម្ចាស់សូមអង្វរបាវនោះឲ្យបន្ធូរបន្ថយបើកឱកាសឲ្យខ្ញុំម្ចាស់និយាយ មួយម៉ាត់សិន ។ គេក៏យល់ព្រមបើកឱកាសឲ្យ; ខ្ញុំម្ចាស់បង្ហើបក្បាលឡើង សំឡឹងមើលប្តីដោយទឹកចិត្តដ៏សោកទន់ភ្លន់ ទើបមានវាចាទៅកាន់គាត់ថា "ឱអនិច្ចាកម្មអើយ! លោកធ្វើបាបខ្ញុំយ៉ាងណាទៅទៀត, ខ្ញុំអស់ផ្លូវសង្ឃឹម ហើយ ខ្ញុំត្រូវតែស្លាប់ក្នុងវ័យកំពុងសប្បាយរបស់ខ្ញុំ" ។ ខ្ញុំម្ចាស់បន្តនិយាយ តទៅទៀត ប៉ុន្តែចៅកែកហើយនឹងសេចក្តីអួលដើមកភាពគឺស្ទះក្នុងក ឃាត់ស្កាត់ដំណើរខ្ញុំម្ចាស់រហូតនិយាយទៀតពុំរួចឡើយ ។ សំដី

---

១. ត្រង់នេះនៅក្បួនក្រុងបាតជាទុ ។

ប៉ុណ្ណោះមិនអាចធ្វើឲ្យខ្ញុំម្ចាស់ឲ្យអាណិតអាសូរបានទេ បែរជាចំអាសទៅវិញ គាត់តែងតែស្តីប្រាសផ្ទួនតិះដៀលថា ចម្លើយរបស់ខ្ញុំម្ចាស់នោះឥតប្រយោជន៍ទាំងអស់ ៗ ខ្ញុំម្ចាស់ក៏តាំងស្រែកអំពាវនាវបួងសួងទេពព្រះធម៌មេបារមីពន់ ប៉ុន្តែគាត់មិនខ្វល់ស្តាប់សោះ បែរជាបង្គាប់បញ្ជាឲ្យធ្វើតាមពាក្យរបស់គាត់ឲ្យឆាប់ៗ ៗ ពេលនោះតាមចួនជាសំណាងល្អ បានយាយតាស៊ីនោរឯងដែលត្រូវជាម្ដាយចិញ្ចឹមរបស់ប្ដីខ្ញុំម្ចាស់ គាត់ចូលមកដល់ភ្លាមហើយក្រាបសំពះប្រណម្យសុំទោសថា "កូនប្រុសម្ដាយ, សូមកូនអាណិតណាស់ណាក្រៃប្រណីដល់នាងនេះ ជាជំនួសថ្ងៃដែលម្ដាយបានចិញ្ចឹមបីបាច់ថ្នាក់ថ្នមកូនតាំងពីតូចមក, សូមកូនពិចារណាមើលចុះថា យើងត្រូវសម្លាប់តែមនុស្សណាដែលសម្លាប់យើង, ចំណែកខាងកូនឯងដែលធ្វើយ៉ាងនេះ ឈ្មោះថាបង្ខូចកេរ្តិ៍ឈ្មោះរបស់ខ្លួន ហើយឈ្មោះថាមិនបាក់សណ្ដាប់ធ្នាប់ដ៏ល្អសម្រាប់មនុស្សជាតិ; កូនធ្លាប់ឃើញឬទេ អ្នកណាដែលប្រព្រឹត្តធ្វើអំពើបាបពេញក្រោលបួនជ្រុងយ៉ាងនេះ?" ៗ យាយតាស៊ីនិយាយពាក្យនេះបណ្ដើរយំខ្សឹកខ្សួលបណ្ដើរ មុខគួរឲ្យអាណិតអាសូរណាស់ សមតែប្ដីខ្ញុំម្ចាស់លុបលើកទោសនោះចោលបាន ប៉ុន្តែគាត់ជាមនុស្សចិត្តដែកបំផុតមិនគិតលស់ណាបានឡើយ គ្រាន់តែបន្ទូរបន្ទុយដោយមាននាទាទៅឆ្លងម្ដាយចិញ្ចឹមថា "ណ្ហើយចុះ ចំណាប់អ្នកម្ដាយមានសេចក្តីស្នេហាចំពោះរូបខ្ញុំ ខ្ញុំក៏ត្រូវតែយោគយល់ទុកតែត្រឹមជីវិតឲ្យ

កៈ ប៉ុន្តែខ្ញុំត្រូវធ្វើឲ្យមានស្លាកស្នាមដើម្បីដាក់ស្តុតាងនៃកំហុសរបស់ក ។

គាត់ថា តែប៉ុណ្ណេះហើយ ក៏បង្គាប់បាវម្នាក់ឲ្យយករំពាត់មួយគួបយ៉ាង ធំ មកវាយវាត់ខ្ញុំម្ចាស់ពេញទំហឹង ត្រង់ខ្នងផងទាំងដើមទ្រូង ទាល់តែរបេះស្បែកដាច់សាច់ហូរឈាមស្រោចស្រពប្រឡាក់ប្រឡូសពាសពេញ ទាំងខ្លួន ដកបដល់ខ្ញុំម្ចាស់សន្លប់បាត់មាត់បាត់កលើងស្មារតី រួចហើយ គាត់ប្រើបាវទាំង ៣ នាក់ដែលទុកដូចជាសេនាបតី នៃចោរសោនោះឯង ឲ្យសែងខ្ញុំម្ចាស់យកទៅដាក់ក្នុងផ្ទះមួយ ។ ជូនជាសក់គឺទព្យាបាលខ្ញុំម្ចាស់ ដោយតារយកចិត្តទុកដាក់យ៉ាងមុតមាំ, ខ្ញុំម្ចាស់ទទួលព្រះកដទានដំណេក ផ្សេងៗតែលើត្រូវចំនួន ៦ ខែ ទើបបានជាស្រស្បះ, ប៉ុន្តែនៅមានស្នាម សំឡាកក្រញីក្រញ៉ាំងពីកាលនោះមក ដូចទ្រង់បានទតឃើញពីម្សិល មិញស្រាប់ហើយ ។ កាលបានជាស្រលះស្រួល អាចដើរចេញទៅក្នុង ទីណាក៏បាន ខ្ញុំម្ចាស់ក៏ត្រូវការវិលត្រឡប់ទៅផ្ទះដែលជាកេរ្តិ៍បិតា ១ របស់ ខ្ញុំម្ចាស់វិញ ប៉ុន្តែទៅដល់ឃើញតែកន្លែងទទេ ព្រោះបុរីពីររបស់ខ្ញុំ ម្ចាស់នោះគាត់ខឹងជ្រុលពេក ប្រើគេឲ្យធ្វើសេចក្តីផ្ទាព្យាបាទដល់ខ្ញុំ ម្ចាស់ប៉ុណ្ណេះហើយក៏នៅតែមិនបាត់ខឹងនៅឡើយ គាត់ឲ្យគេកាប់គាស់ រុះរើបំផ្លិចបំផ្លាញផ្ទះសម្បែងព្រមទាំងទ្រព្យសម្បត្តិរបស់ខ្ញុំម្ចាស់ ទាំង អម្បាលម៉ាននោះពោលគឺសល់លើងថែមទៀត ដើម្បីជិនានសខ្ញុំម្ចាស់ ។

(មានត)

# ព្រះរាជប្រវត្តិ

## ព្រះបាទសម្តេចព្រះជ័យជេដ្ឋា (ព្រះអង្គស្ងួន)

(តមក)

ក្រោយនោះសម្តេចព្រះជ័យជេដ្ឋា ទ្រង់ប្រជុំសេនាបតីមន្ត្រីផង ទាំងពួងថា ឥឡូវយើងគោលព្រះរាជកំណត់ទុគ្គមានជ័យយូរហើយ បណ្តាស្រុកតែខ្ទាតខ្ទាយអស់ទៅច្រើន គួរយើងត្រឡប់ទៅគង់ព្រះរាជកំណត់ទុគ្គមានជ័យវិញ អស់នាហ្មឺនសព្វមុខមន្ត្រីក៏យល់ព្រមតាមព្រះពុទ្ធដីកា ។ ទើបស្តេចអញ្ជើញសម្តេចព្រះទាវក្សត្រីព្រមទាំងព្រះស្នំព្រះម្នាង ទៀងគង់ព្រះទីនាំងគជេន្ទ្រ នាហ្មឺនសព្វមុខមន្ត្រីនាយទ័ពនាយផង ក៏ហែស្តេចចេញពីព្រះពន្លាតកកណ្តាល ប្រាំពីរម៉ឺនមកគង់ក្រុងទុគ្គវិញ រួចត្រាស់បង្គាប់សេនាទាហានដាក់យាមល្បាត រៀងតាមមាត់ទន្លេទៅទល់និងភ្នំពេញ- ក្រោយបន្ទា បង្ការក្រែងទ័ពព្រះបទុមរាជាលើកមកវិញទៀត ។ ។

## ព្រះជ័យជេដ្ឋាទ្រង់បង្វែររាជសម្បត្តិថ្វាយ ព្រះវររាជមាតា ស្តេចចេញទៅទ្រង់ព្រះផ្នួស ៣ ខែ

លុះដល់ឆ្នាំរកាសម្រិទ្ធិស័ក (ព.ស. ២២៣២) ព្រះអគ្គក្សត្រីព្រះរាជទេពីសម្តេចព្រះជ័យជេដ្ឋា ប្រសូតព្រះរាជបុត្រ ១ អង្គ ព្រះនាម

ជាអនុជាតក្សត្រី ។ ក្នុងឆ្នាំរោងសម្រឹទ្ធិស័កនេះ សម្ដេចព្រះជ័យជេដ្ឋា ទ្រង់ព្រះប្រឈួនព្រះគណ្ឌរោគតឹកដាំ ទ្រង់បង្វែររាជសម្បត្តិថ្វាយព្រះវររាជមាតា ឲ្យទ្រង់គ្រប់គ្រងជំនួសបីខែ លុះសះជាព្រះរោគមានព្រះទ័យត្រេកថ្វា ទ្រង់បព្វជ្ជាជាភិក្ខុគង់នៅវត្តព្រះសុគន្ធមានបុណ្យ ៧ ថ្ងៃ សេនាបតីមន្ត្រីនាំគ្នាទៅក្រាបបង្គំទូល ឲ្យស្ដេចលាកសិក្ខាបទមកគ្រប់គ្រងរាជសម្បត្តិវិញ ។

## មន្ត្រីធំពីរនាក់ក្បត់រត់ទៅបួលនឹងរាជសត្រូវ

លុះដល់ឆ្នាំម្សាញ់ឯកស័ក (ព.ស. ២២៣៣) សម្ដេចចៅពញា (នូរ) ១ ចិនតាំងចុងអៀ ១ និតគួបចិត្តនឹងសម្ដេចព្រះជ័យជេដ្ឋា ដែលទ្រង់ព្រះរាជទានរង្វាន់ទីងយសស័ក្តិ ។ ដល់ចៅពញាកក្តិសង្គ្រាម (ហុក) នឹងឧកញ៉ាទ័យធិរាជ (សោម) ក៏មានសេចក្តីប្រណែន ទើបប្រឹក្សាគ្នាស្រេចលបលួចរត់ទៅចូលសម្ដេចព្រះបទុមរាជា នៅនៃត្រស្រីសឈរ ។

សម្ដេចព្រះបទុមរាជាទ្រង់ជ្រាបមានព្រះទ័យត្រេកអរ ត្រាស់ថា សម្ដេចចៅពញា (នូរ) នេះ ជាមនុស្សចាស់គាំងពីព្រះវររាជបិតាមាតាយើងមក ឥឡូវរត់មកចូលនឹងយើង ដោយមិនចូលចិត្តនឹងព្រះជ័យជេដ្ឋា គួរយើងទទួលយកចុះ ហើយទ្រង់ឲ្យនាំសម្ដេចចៅពញា (នូរ) នឹងចិនតាំងចុងអៀ ព្រមទាំងបក្ខពួកចូលគាល់ ទ្រង់ត្រាស់សួរហេតុ

សត្រូវគប់ ។ សម្តេចព្រះបទុមរាជា ទ្រង់ជឿមិនសង្ស័យ ដោយសម្តេចចៅពញា (ឡូ) ធីងប៊ិនគាន់បុនអៀ យកតាំងប្រពន្ធកូនទៅផង ទើបទ្រង់ឲ្យរួចតាំងពីរ ទទួលព្រះរាជទានទឹកព្រះពិព្ទសច្ចាស្បថតាមទំនៀមចក្រាសេក ។

លុះសម្តេចព្រះជ័យជេដ្ឋា ទ្រង់ជ្រាបថា មន្ត្រីធំទាំងពីរនាក់តែងទៅបូលនឹងរាជសត្រូវដូច្នោះ ក៏ទ្រង់ខ្ញាល់ណាស់ ទើបស្ដេចឲ្យប្រមូលសេនាទាហានស្បៀងអាហារនិងទូក ព្រមទាំងគ្រឿងសស្ត្រាវុធបម្រុងនឹងលើកទៅវាយទ័ពព្រះបទុមរាជា ។ កាលទ្រង់ជ្រាបថា សម្តេចព្រះជ័យជេដ្ឋាប្រមូលសេនាទាហាននឹងលើកមកច្បាំង ទ្រង់ក៏ប្រឹក្សានឹងពួកនាយទ័ពណាយចង់ថា គួរព្រះជ័យជេដ្ឋាចយកកំឡាំងហើយ ដ្បិតសម្តេចចៅពញា (ឡូ) ជាមនុស្សចាស់មានសតិបញ្ញាច្រើន ធីងប៊ិនគាន់បុនអៀមានទ្រព្យសម្បត្តិច្រើន មកនៅក្នុងកណ្តាប់ដៃយើង ឥឡូវពួកដំណឹងថា ប្រឹងប្រែបរៀបទ័ពនឹងលើកចូលមក ត្រូវយើងចាត់កងទ័ពទៅស្ទាក់ច្បាំងកុំឲ្យចូលមករួច បើមានជ័យជំនះនឹងលើកទ័ពដេញព្រះជ័យជេដ្ឋាឲ្យខ្ចាត់ចេញពីព្រះនគរ យើងនឹងទៅនៅក្នុងព្រះរាជវាំងដុនផ្តួចជ័យវិញ ។ អ្នកធំមន្ត្រីនាយទ័ពទាំងពួងក៏យល់ព្រម ទើបទ្រង់ចាត់សម្តេចចៅពញា (ឡូ) ធីងប៊ិនគាន់បុនអៀជាមេទ័ពធំនាំសេនាទាហាន ១៥,០០០ បុរុសកំពង់ស្វាយមាស ចូលបីនរាលសំណាបឯដើង ។

# ព្រះរាជសង្គ្រាមគ្រាទី ៤

## ចម្បាំងជើងទឹកទ័ពព្រះបទុមរាជាបរាជ័យ

ថ្ងៃ ៦ កើតខែមិគសិរឆ្នាំម្សាញ់ឯកស័ក . (ព.ស.២២៧៣)

សម្តេចចៅពញា (ឡូ) ទ័ពចិនកាន់ចុងអៀមទ័ពធំតាំងពីរកំលើចព្យហ៍ យាត្រាចេញតាមព្រែកផ្លូវត្រី ដល់ទន្លេឡើងវៀនមកបោះទ័ពនៅត្រើយល្វាឯម ក៏ចាត់ទ័ពឲ្យចូលមកវាយបន្ទាយជ្រោយចង្វា ។ ឯទ័ពខាងចៅពញាតក្កីសង្គ្រាម បានឃើញទ័ពត្រើយខាងកើតប្រែទណាក សំគិត ស្មានថា សម្តេចព្រះបទុមរាជាលើកមក ក៏ពុំបានទទួលបង្កាំងទើបនាំគ្នាចូលពីបន្ទាយជ្រោយចង្វាមកប្រជុំនៅទីទ័ព ឲ្យកញ្ញាំ ទទ័យធាកផុំនៅក្នុងពេញ ហើយប្រឹក្សាគ្នាថា សម្តេចព្រះបទុមរាជាលើកទ័ពមកគ្រានេះប្រែនលើសលើង ដែលស្តេចឲ្យកេណ្ឌសេនាទាហានបញ្ជូនមកទៀតក៏ពុំទាន់ឃើញមកដល់ ត្រូវយើងចាត់សេនាទាហានឲ្យទៅក្រាបទូលសុំឲ្យបញ្ជូនពលថែមទៀតជាប្រញាប់ ឯយើងត្រូវថយទ័ពទៅបោះឲ្យឆ្ងាយពីមាត់ទន្លេសិន តែត្រូវចាត់សេនាទាហាន ២០០០ ឲ្យនៅរក្សាបន្ទាយក្នុងពេញ ចាំទទួលបង្កាំងទ័ពពួកត្រើយខាងកើតកុំឲ្យឡើងគោករួច ចាំទ័ពពីក្រុងមកដល់សិន លុះព្រមព្រៀងគ្នាហើយក៏ថយទ័ពទៅបោះនៅស្ទឹងទទឹងថ្ងៃ ។ ឯសម្តេចព្រះបរមបពិត្រ ទ្រង់ជ្រាបរាជការសង្គ្រាមសព្វគ្រប់ហើយ ក៏ទ្រង់ចាត់ទ័ពជើងទឹក ៨០០០ ទ័ពគោក ៥០០០

ប៉ុស្តិ៍ខុតជាស្រេច ឯទ័ពយួនក៏លើកចូលមកក្រុងពេញ ទ័ពខាងចៅពញ្ញាអគ្គីស្រ្គាមធិបតីញ្ញាទ័យពិជមិនបានទទួលបង្រាំង ហើយថយមករួមនឹងទ័ពធំ ទ័ពយួន-ខ្មែរក៏លើកតាមមកបង្រាំងនៅស្ទឹងទទឹងថ្ងៃ ចៅពញ្ញាអគ្គីស្រ្គាមធិបតីញ្ញាទ័យពិជ ក៏នាំសេនាទាហានចេញបង្រាំងបានកាប់សម្លាប់យួន-ខ្មែរស្លាប់ជាច្រើននៅមាត់បឹងជាខាងកើតស្ទឹងទទឹងថ្ងៃ ទ័ពយួន-ខ្មែរក៏ដោះថយចូលទៅបន្ទាយព្រៃយាបត្បូងទីងត្រើយល្ងមវិញ ។

ថ្ងៃ ៥ កើតខែបុស្សឆ្នាំម្សាញ់ឯកស័ក (ព.ស. ២២៣៣) ទ័ពចាំងពីគេងលើកចេញពីក្រុងធុន្តព្ធ័យមកដល់ក្រុងពេញ នោះចៅពញ្ញាអគ្គីស្រ្គាមបុគធិនចៅពញ្ញាទ័យពិជបានដឹងថា ទ័ពពីក្រុងមកដល់ក្រុងពេញ ក៏លើកទ័ពពីស្ទឹងទទឹងថ្ងៃ ទៅរួបរួមគ្នានៅក្រុងពេញឈប់សម្រាកកំឡុង ៦ យប់ ។

ថ្ងៃ ៦ កើតខែបុស្សឆ្នាំដដែលនេះ ចៅពញ្ញាអគ្គីស្រ្គាមចាត់សេ-នាទាហានជើងទឹក ៨០០ នាក់ ឲ្យចុះទូកលើកទៅវាយបន្ទាយព្រៃយាបត្បូង ស្ដេចចៅពញ្ញា (ទូ) នឹងចិនតាន់ចុងអៀ ឲ្យសេនាទាហានចុះទូកមកទាកទល់គ្នានៅព្រៃយាបត្បូង សេនាទាហានទាំងសងខាងបានបាញ់គ្នាទៅវិញទៅមក ហើយចូលប្រតាប់ប្រតាក់គ្នាជាវែក សេនាទាហានត្រើយខាងលិចដែលនៅលើគោក បានបាញ់កាំភ្លើងធំទៅត្រូវទូកខ្មែរ-យួនទ័ព

ត្រើយខាងកើតលិចលង់ស្លាប់ច្រើន ក៏បរទូកឡើងទូកធំ ចៅពញ៉ា កក្តីស្រ្គាម ក៏នាំសេនាពលហានចុះទូកដេញ តាមទៅទាន់ឡើងទូកធំប្រ-តាប់ប្រហារគ្នា ពលខ្មែរ-យួនស្លាប់ដេរដាស ចាប់បានចាំហ្វ៊ូនសម្តេចចៅពញា (ឌូ) និងចិនតាន់ចុងអៀ ព្រមទាំងសេនាពលហានជាច្រើន និងទូកត្រៀងសស្ត្រាវុធ មានពួកសេនាពលហានខ្លះ រំកុំទូកតូចឡើងគោកទៅខែត្រស្រីសុឈរវិញ ក្រាបទូលសម្តេចព្រះបទុមរាជាឲ្យទ្រង់ជ្រាបគ្រប់ប្រការ ក៏ទ្រង់ព្រួយព្រះទ័យឡៃក្រៃពេក(១) ។

---

១ — តាមច្បាប់សាស្ត្រាស្ទឹករវិគមានសេចក្តីសង្ខេបថា កាលពីឆ្នាំជូតអដ្ឋស័កនោះ ព្រះអង្គឧទ្ទិយោពរាជស្តេចនៅស្រុកយួន ទ្រង់នាំទ័ពចិន (មិនមែនទ័ពយួន) ឡើងមកបញ្ចុះបញ្ចូលបានស្រុកស្រីសឈរ ហើយសាងព្រះរាជវាំងគង់នៅស្រុកស្រីសឈរ ទ្រង់ឲ្យលើកទ័ពមកច្បាំងនឹងសម្តេចព្រះជ័យជេដ្ឋាបរមសុរិន្ទ្រ ច្បាំងគ្នាពីឆ្នាំជូតដល់ឆ្នាំម្សាញ់ពុំចាញ់ពុំឈ្នះថយទ័ពទៅដោយខ្លួន ។ ឯសម្តេចព្រះជ័យជេដ្ឋាព្រះជន្មបាន ២៧ វស្សា ទ្រង់ព្រះអាពាធព្រះកណ្ឌរោគ ស្តេចបង្វែររាជសម្បត្តិថ្វាយសម្តេចព្រះវររាជជននីនាថ លុះកណ្ឌរោគសះជាហើយទ្រង់ព្រះផ្នួស ៧ ថ្ងៃ សឹកព្រះផ្នួសចេញ ។ លុះដល់ឆ្នាំរោងទោស័ក នោះសម្តេចពញាកាន់ជាតាហ្លួន ១ ចិនតាន់ចុងអៀម ១ ក្បត់ចេញជាសត្រូវនឹងសម្តេចព្រះជ័យជេដ្ឋាទៅចូលពឹងអ្នកអង្គឧទ្ទិយោពរាជ ឯព្រះរាជវាំងស្រុកស្រីសឈរ នោះអ្នកអង្គឧទ្ទិយោពរាជប្រើឲ្យសម្តេចចៅពញាកាន់នឹងចិនតាន់ចុងអៀម ឲ្យនាំពលខ្មែរ-ចិនលើកទ័ពមកច្បាំងនឹងសម្តេចព្រះជ័យជេដ្ឋាចេស្តា ៗ ច្បាំងឈ្នះបានសំពៅ ៤ ផង នឹងអ្នកអង្គអី ព្រះរាជបុត្រីសម្តេចព្រះបទុមរាជាជាព្រះភាគិនេយ្យដែលជាប់មកនឹងសំពៅជាព្រះរាជទេពី ។ លុះដល់ឆ្នាំម្សាញ់ត្រីស័ក អ្នកអង្គឧទ្ទិយោពរាជមកច្បាំងទៀត សម្តេចព្រះជ័យជេដ្ឋាទ្រង់ច្បាំងឈ្នះទៀត ដេញទ័ពយួនរត់ទៅស្រុកយួនវិញ ។ ទើបព្រះជ័យជេដ្ឋាស្តេចទទួលយករាជសម្បត្តិអំពីព្រះវររាជជននីនាថមកវិញ ទ្រង់ព្រះនាមជា ព្រះបាទសម្តេចព្រះរាជឱង្ការព្រះជ័យចេស្តាបរមសុរិន្ទ្រាធិរាជរាមាធិស្វរ ស្តេចលើកអ្នកអង្គអីជាព្រះមហេសីទ្រង់ព្រះនាម ព្រះភគវតីស្រីបរមចក្រព័ត្តិរាជក្សត្រី ។

ក្រោយនោះ ចៅពញាកក្តីសង្គ្រាមឲ្យព្រៀបព្រួចទុកស្រាប់ផងនឹង សេនាទាហានដែលចាប់បានទាំងប៉ុន្មានក្នុងសង្គ្រាម ឲ្យនាំទៅថ្វាយសម្តេចព្រះជ័យជេដ្ឋា នៅព្រះបន្ទាយកំពង់ក្តួលមានជ័យ ហើយឲ្យនាំទាំងសម្តេចចៅពញា (នូរ) និងចិនគាន់ចុងអៀទៅថ្វាយផង ហើយក្រាបបង្គំសព្វគ្រប់សេចក្តី ។ សម្តេចព្រះបរមបពិត្រទ្រង់មានព្រះអំណរក្រៃអរណាស់ ស្តេចឲ្យនាំខ្លួនចូលថ្វាយទាំងក្នុង ទ្រង់ទតឃើញសម្តេចចៅពញា (នូរ) និងចិនគាន់ចុងអៀ ទ្រង់ព្រះក្រោធណាស់ ត្រាស់ជេរព្រះសួរសៀងជាខ្លាំង ថាសម្តេចចៅពញា (នូរ) នេះ យើងចិញ្ចឹមឲ្យធ្វើជាសម្តេចចៅពញា ផ្សេងជាខ្ញុំពុជតារបស់ពីសម្តេចព្រះវររាជបិតា គួរតែមានចិត្តកតញ្ញូដល់ព្រះវររាជបិតាយើងដែលទ្រង់មានព្រះគុណ ផ្ទួរត្រឡប់ជាសត្រូវនឹងយើងវិញ សម្តេចចៅពញាមិនស្រឡាញ់យើងៗ ក៏មិនស្រឡាញ់សម្តេចចៅពញា រួចទ្រង់ព្រះរាជបញ្ជាអកហ្ម៉ឺនពាមចៅបុរីគ្រូ (អ៊ិន) ឲ្យនាំសម្តេចចៅពញា (នូរ) និងចិនគាន់ចុងអៀទៅប្រហារជីវិត ដោយកាត់ក្បាលទៅបន្ទាយព្រៃយបង្ហាជាបម្រាម កុំឲ្យអ្នកទាំងពួងយកជាបែបយ៉ាងតទៅ ពលទាំងប៉ុន្មានឲ្យបញ្ជូនដាក់ចំណងអស់ ។

ថ្ងៃក្រោយ សេនាបតីមន្ត្រីរាជការទាំងពួង ដ៏ទុំព្រមរៀបពិធីប្រាប្ដាភិសេក(១)តាមទំនៀម ហើយអញ្ជើញសម្ដេចព្រះជ័យជេដ្ឋាឡើងសោយរាជសម្បត្តិតាមខត្តិយប្រវេណី ។

## ព្រះជ័យជេដ្ឋាទ្រង់បានប្រាប្ដាភិសេក

ពុទ្ធសករាជ ២២៣៣ មហាសករាជ ១៦១១ ចូឡសករាជ ១០៥១ ថ្ងៃ ៥ កើត ខែផល្គុន ឆ្នាំម្សាញ់ឯកស័ក វេលាព្រឹក ប្រកបដោយឫក្សជាមង្គលដ៏ឧត្ដម សម្ដេចព្រះជ័យជេដ្ឋាស្ដេចគ្រងរាជសម្បត្តិមកបាន ១៥ វស្សា គិតព្រះជន្មាយុ ៣០ ព្រះវស្សា ស្ដេចឡើងប្រាប្ដាភិសេកសោយរាជសម្បត្តិ ព្រះរាជគ្រូបុរោហិតថ្វាយព្រះរាជអភិសេកតាមប្រវេណី ទ្រង់ព្រះនាមថា ព្រះបាទសម្ដេចព្រះរាជឱង្ការព្រះជ័យជេស្ដាមហា ឥស្សូរបរមសុរិន្ទកម្ពុជនាថបរមខត្តិយជាតិ សុរិយោវង្សពង្សពុទ្ធាធិបតីសិរី-ធម្មិករាជា បរមចក្រពត្តិរាជ មហាមហិទ្ធិបតិស្សរៈបវរសុរិន្ទអង្គជ័យត្រៃរតនៈមកុដវិសុទ្ធមុនី ព្រះស្រីបរមទេពជនសារសុទ្ធបវរមកដាធិរាជបរមនាថបរមបពិត្រ គង់ក្នុងព្រះបរមរាជវាំងដ៏ឧត្ដុង្គជ័យ (២) ។ ទ្រង់អភិសេក

---

១ ប្រែតាមរូបស័ព្ទថា "មានអភិសេកដល់ហើយ" សំដៅចំពោះដល់ព្រះមហាក្សត្រដែលច្បាំងឈ្នះសង្គ្រាម បានទទួលរាជាភិសេកឡើងគ្រងរាជសម្បត្តិ មានសេចក្ដីហណ៍ដូចជាព្រះបាទសម្ដេចព្រះជ័យជេដ្ឋានេះជាដើម ។ ២ ព្រះបាទសម្ដេចព្រះជ័យជេដ្ឋា (ព្រះអង្គសួរ) តាំងពីស្ដេចបានប្រាប្ដាភិសេកមកទ្រង់ព្រះនាមជាព្រះបាទសម្ដេចព្រះជ័យជេស្ដា តាំងពីនោះមកគេក៏ហៅព្រះនាមថ្មីនេះរហូតមកដល់សម័យសព្វថ្ងៃនេះ ។

ព្រះអគ្គអគ្គក្សត្រីជាព្រះអគ្គមហេសី ទ្រង់ព្រះនាមថា សម្តេចព្រះភគវតី សិរីពក្រភត្តមហាក្សត្រី ។

## ព្រះរាជសង្គ្រាម គ្រាទី ៥
## ទ័ពព្រះបទុមរាជាបរាជ័យទៀត

ក្នុងឆ្នាំវេលានេះ សម្តេចព្រះបទុមរាជាមហាឧបយោរាជផុខ ទ្រង់ជ្រាបថា សម្តេចព្រះជ័យជេដ្ឋាស្តេចបានប្រាក្តាភិសេកឡើងសោយរាជសម្បត្តិ ។ ទ្រង់ព្រះនាមជា ព្រះជ័យជេស្ឋាដូច្នោះ ទ្រង់ព្រួយព្រះទ័យណាស់ ទើបទ្រង់ប្រឹក្សានឹងមន្ត្រីទាំងពួងថា ព្រះជ័យជេដ្ឋាឡើងសោយរាជ្យហើយ ។ ពួកមន្ត្រីមុខងារនៃមានសតិបញ្ញាប្រែនជាងយើង គេប្រហែលជានឹងលើកទ័ពធ្វើមកធ្វើសង្គ្រាមនឹងយើងទៀតពុំខាន ឥឡូវសេនាទាហានខាងយើងមានតិច ត្រូវយើងចុះទៅពឹងព្រះចៅក្រុងអណ្ណាម ទូលសុំពលយួនមកជួយទៀតគង់តែមានជ័យជំនះ ។ ពួកមន្ត្រីទាំងនោះគំយល់ព្រម ទើបស្តេចចុះគង់ព្រះទីនាំងនាវាធ្វើព្រះរាជដំណើរទៅដល់ស្រុកយួនក្រាបទូលព្រះចៅក្រុងអណ្ណាមសុំទាហានទៅជួយច្បាំង ស្តេចយួនក៏ប្រោសសេនាទាហានចំនួន ១០,០០០ សម្តេចព្រះបទុមរាជាក៏ថ្វាយបង្គំលាស្តេចយួនទាំងទ័ពយួនឡើងមក ទ្រង់ឡើងចុះទ័ពនៅក្រោយហ្វៀងម ។

ព្រះបាទសម្ដេចព្រះជ័យជេដ្ឋាទ្រង់ជ្រាបថា សម្ដេចព្រះបទុមរាជា ស្ដេចលើកទ័ពយួនឡើងមកវិញទៀត ក៏ត្រាស់បង្គាប់ឲ្យរៀបចំទ័ពជើងទឹកជើងគោកបំរុងចុះជាប្រញាប់ រួចលើកចេញពីក្រុងឧត្ដុង្គឫជ័យសំដៅទៅភ្នំពេញក្រោយចន្ទា បានវាយច្បាំងគ្នានៅទីនោះ ទ័ពខាងលិចមានជ័យជំនះ សម្លាប់ពលខ្មែរ-យួនស្លាប់អស់ជាច្រើន សម្ដេចព្រះបទុមរាជា ក៏ទ្រង់លើកទ័ពទៅបោះនៅខែត្រស្រីសឈរ ពួកសេនាទាហានយួនក៏ថយបង្គំលាត្រឡប់ទៅស្រុកយួនវិញ ។ ការបរាជ័យគ្រានេះនឹងគ្រាមុនៗ ជាហេតុនាំឲ្យសម្ដេចព្រះបទុមរាជា ក្រៀមក្រំព្រះទ័យបង្កកើតទៅជាព្រះរោគឡើង ។

លុះដល់ឆ្នាំមមីទោស័ក (ព.ស. ២២៣៤) សម្ដេចព្រះកករតិសិរីបក្រពត្តិ ជាព្រះអគ្គមហេសីព្រះបាទសម្ដេចព្រះជ័យជេដ្ឋា ប្រសូតិព្រះរាជបុត្រា ១ អង្គព្រះនាមព្រះស្រីធម្មរាជា ។

ក្នុងឆ្នាំដដែលនេះ ព្រះបាទសម្ដេចព្រះជ័យជេដ្ឋាទ្រង់ប្រោសប្រទានតាំងព្រះអង្គយ៉ង់ជាព្រះភាគិនេយ្យា ព្រះរាជបុត្រាសម្ដេចព្រះកែវហ្វា (ព្រះអង្គជី) ឲ្យទ្រង់ព្រះនាមជាព្រះឧទ័យរាជា រួចទ្រង់ផ្សំព្រះឧទ័យរាជានឹងព្រះសុជាតាវតីព្រះរាជបុត្រីសម្ដេចព្រះបរមរាជា (ព្រះអង្គសូរ) ជាព្រះអនុជព្រះអង្គបង្កើត តែផ្សេងព្រះមាតា ត្រូវជាព្រះមាតុលារបស់ព្រះឧទ័យរាជា ឲ្យជារាជពន្ធិកា ។

ដល់ឆ្នាំមមែ ត្រីស័ក (ព.ស. ២២៣៥) សម្ដេចព្រះបរមរាជា (ព្រះអង្គចន្ទ) ព្រះជន្ម ៣៨ វស្សា [១] ទ្រង់ព្រះរោគាពាធជាទម្ងន់ សោយព្រះទិវង្គតនៅវាំងស្រីសឈរ នោះព្រះអង្គ (អិម) ជាព្រះរាជបុត្រា នឹងមន្ត្រីខ្ញុំរាជការ ប្រញាប់ការធ្វើបុណ្យថ្វាយព្រះភ្លើងរំលាយព្រះបរមសព ដោយប្រញាប់ ៗ ក្នុងខណៈនោះ ព្រះអង្គ (អិម) ព្រះជន្មបាន ១៧ វស្សា នៅក្នុងបឋមវ័យ ស្រាលសេចក្ដីពុំទាន់ចេះរិះគិតការធ្ងន់ស្រាល តាមចិត្តតែនឹងមនុស្សប្រចុបប្រចែងបះបោរ ទើបពួកមន្ត្រីដែលសុចរិតស្មោះត្រង់ទាំងប៉ុន្មាន ក៏នាំគ្នារត់មកជ្រកកោនក្រោមព្រះពោធិសម្ភារព្រះបាទសម្ដេចព្រះជ័យចេស្ដា ក្រាបបង្គំទូលរៀបរាប់សព្វគ្រប់ប្រការ ។

## ទ្រង់ចាត់មន្ត្រីឱ្យទៅទទួលយក ព្រះអង្គអិម រាជបុត្រ ព្រះបរមរាជា

លុះព្រះបាទសម្ដេចព្រះជ័យចេស្ដា កាលព្រះអង្គទ្រង់ជ្រាបថា សម្ដេចព្រះបរមរាជាទិវង្គតហើយ នៅតែព្រះអង្គ (អិម) ជាព្រះរាជបុត្រា ទើបទ្រង់ប្រឹក្សានឹងសេនាបតីមន្ត្រីថា គួរយើងទៅទទួលយកអង្គ (អិម) មកទុកក្នុងក្រុង កុំឲ្យគិតការធ្វើសង្គ្រាមតទៅទៀត ។

---

១ ច្បាប់ពង្សាវតារស្លឹករឹតថា ព្រះជន្មបាន ៥៣ វស្សាទ្រង់ព្រះអាពាធសុគតទៅនៅក្រុងកំពង់ស្រីសឈរ ។

ពួកសេនាបតីមន្ត្រីក៏យល់ព្រមតាមព្រះរាជតំរិះ ទើបទ្រង់តាំងឲ្យអកហ៊ិន ហោមវៃបុរីរក្ស (អ៊ិន) នាំសេនាទាហាន ១០០ ចុះទូកចូលទៅខែត្រស្រីសឈរ ។

ឯព្រះអង្គ (អិម) បានទ្រង់ជ្រាបដំណឹងដូច្នោះ ក៏ទ្រង់ប្រឹក្សានឹងពួកអស់ការដែលទុកព្រះទ័យថា ឥឡូវសម្តេចព្រះជ័យជេស្ឋា ឲ្យមន្ត្រីមកទទួលយើងចូលទៅនៅក្រុង តើអ្នកទាំងពួងយល់ដូចម្តេច ។ ពួកមន្ត្រីទាំងនោះទូលថា យើងចូលទៅពុំបានដោយជាប់សង្គ្រាមនឹងគ្នា តែយើងនឹងរៀបច្បាំងតតាំងនឹងគេពុំបាន ដ្បិតសេនាទាហានយើងមានតិច សេនាទាហានគេទៅចូលគេអស់ គួរដោះខ្លួនទៅពឹងស្តេចយួនសិន សឹមគិតគូធ្វើសង្គ្រាមជាក្រោយ ព្រះអង្គអិមក៏ទ្រង់យល់ព្រម ។ ហើយស្តេចប្រមូលនាំពួកអស់ការដែលទុកព្រះទ័យបាន ៩០ នាក់ ស្តេចចុះទូកទៅស្រុកយួនចូលគាល់ក្រាបបង្គំទូលព្រះចៅក្រុងអណ្ណាម តាមដំណើរសព្វគ្រប់ ។

ឯអកហ៊ិនហោមវៃបុរីរក្ស ចុះទូកទៅដល់ខែត្រស្រីសឈរហើយ ទើបបានដឹងថា ព្រះអង្គ (អិម) ស្តេចចុះទៅស្រុកយួននឹងលើកទៅតាមពុំទាន់ ក៏ប្រមូលព្រះរាជទ្រព្យពីសម្តេចព្រះបទុមរាជាដែលសេសសល់នៅខ្ទះនោះ នាំមកថ្វាយនៅក្រុងឧត្តុង្គជ័យ ក្រាបបង្គំទូលឲ្យទ្រង់ជ្រាបគ្រប់ប្រការ ។ ក្រោយនោះហៅហ្វាយខែត្រគ្រប់ខែត្រទាំងអស់ទៅ

ត្រូវបានកើតនាំគ្នាមកពីនព្រះបរមពោធិសម្ភារព្រះបារមី ព្រះនាង ក៏ចំរើនរុងរឿងដោយព្រះមហាក្សត្រទ្រង់ទសពិធរាជធម៌ ស្ដេចចេញវិនិច្ឆ័យកាត់សេចក្ដីដោះទុក្ខក្រដោយព្រះអង្គឯង ។

(កាលស្ដេចពុំទាន់បានប្រាប្ដាភិសេកនោះ ស្ដេចទ្រង់ផ្ដៀតផ្ដាក់ច្បាប់តាំង ២៤ ក្រម ស្ដេចរៀបរៀងផ្ដៀតផ្ដាក់ពុំទាន់បប់សព្វគ្រប់) ។

លុះដល់ឆ្នាំរកាត្រីស័ក (ព.ស. ២២៣៦) ព្រះសុជាតវតីជារាជវនិតា ព្រះទ្រង់យកជា ព្រះអគ្គយ័ន ប្រសូតព្រះរាជបុត្រា ១ អង្គ ព្រះនាមព្រះអង្គតន់ ។

ក្នុងឆ្នាំដដែលនេះ ព្រះរាជវង្សតាមសៅប៊ីនរ៉ុបប៊ីនកិន កើតចាស់ ខែឧនិនយួនខ្លះ មានអំណាចលើពេទ័ពដេញតួតហាមផ្សាៗ ដោះរកមក ពីនព្រះបរមពោធិសម្ភារចំនួន ៥,០០០ ត្រួ ។ ទ្រង់ព្រះមេត្តាប្រោសឲ្យតាំងទីលំនៅៗ ខែត្រព្យូងឃ្លុំខ្លះ ខែត្រស្នឹងត្រង់ខ្លះ ព្រៃជាយបន្ទាត់ខ្លះ ព្រែកប្រាខ្លះ បានជាជាប់ហៅភូមិផ្សារៀនមក ឯស្រុកប៊ីនរ៉ុបប៊ីនកិនក៏បានទៅយួនលុះដល់សព្វថ្ងៃនេះ ។

## អំពីទ្រង់កសាងព្រះអារាម

លុះដល់មកឆ្នាំអាចព្ទស័ក (ព. ស. ២២៣៧) សម្ដេចព្រះរាជក្សត្រ ជាព្រះវររាជជននី ទ្រង់មានព្រះរាជហឫទ័យ នឹងព្រះបាទសម្ដេចព្រះ

ផ្ទៃបេស្តាផាព្រះរាជបុត្រថា យើងចង់ទៅធ្វើបុណ្យសងគុណទឹកដីព្រៃ ដំណែល ដែលរះចៅពញាកក្តីសន្ត្រាម ( ហុក ) នាំយើងរត់ពីភ័យសត្រូវ ទៅពួនទៅគ្រប់គន្ទេន ។ សម្តេចព្រះរាជបុត្រក៏ទ្រង់យល់ព្រមតាមរាជ-ហឫទ័យ ហើយទ្រង់ចាត់ចៅពញាកក្តីសន្ត្រាមឲ្យចេញទៅកេណ្ឌរាស្ត្រ លើកដីពូនភឿនកាប់ឈើធ្វើព្រះវិហារសាលាកុដិ នៅទីព្រះពន្លាកឋ កណ្តាលព្រាំតម្បូង ១ សន្ទី ។

ទ្រង់ព្រះមេត្តាប្រោសពញាគោត ឲ្យឡើងយសសក្តិជាចៅពញាធម្ម ដោយមានគុណបំណាច់ បានទៅច្បាំងជាមួយចៅពញាកក្តីសន្ត្រាម រួចត្រាស់ប្រើឲ្យទៅកេណ្ឌរាស្ត្រកាប់ឈើ ធ្វើវិហារសាលាកុដិជាព្រះអារាមនៅទីព្រៃពួន ១ អន្លើ ឲ្យលើកដីពូនភឿនឲ្យខ្ពស់សានឲ្យល្អជាងវត្តឯទៀត ។ ដ្បិតជាទីស្តេចប្រថាប់ជារឿយៗ រួចជីកស្រះនៅខាងមុខវត្តឲ្យវែងធំទូលាយ ដើម្បីឲ្យដាក់ទឹកជាប់ជានិច្ចទុកជាទានដល់ភិក្ខុសាមណេរ និងជនានុជនទាំងពួង ។

ទ្រង់ព្រះមេត្តាប្រោស ភាគ់អចហ៊ានបោមបៃបុងរក្ស ( អ៊ិន ) ជាចៅពញាតេជោចៅហ្វាយស្រុកខែត្រសំពៅទង ហើយទ្រង់ត្រាស់បង្គាប់ឲ្យចេញទៅកាប់ឈើសាងព្រះវិហារសាលាកុដិជាព្រះអារាម នៅទួលទ្រើង ១ អន្លើ ។ ឯសាងវិហារសាលាកុដិធ្វើជាព្រះអារាមនៅត្រង់អន្លើ ដែលសម្តេចព្រះវររាជជននីទ្រង់ទតឃើញមេភោបំបៅកូន កន្លែងព្រៃ

ថាទីពុអន្ទើ (?) ។ លុះសាងរួចស្រេចក៏នាំគ្នាយកសេចក្ដីក្រាបបង្គំទូល ឲ្យទ្រង់ជ្រាបគ្រប់ប្រការ ។

ថ្ងៃ ១ កេតខែពិសាខឆ្នាំចឆស័ក ( ព. ស. ២២៣៨ ) ស្ដេចអញ្ជើញ ព្រះវរជននី ព្រមទាំងព្រះអគ្គមហេសីព្រះស្រីស្រិគ្គារ សេនាបតី នាហ៊ឺនសព្វមុខមន្ត្រីព្រះរាជដំណើរចេញទៅធ្វើព្រះរាជកុសល នៅព្រះ ពន្លាកណ្ដាលប្រាំតម្បឹងនៅចុងខែត្រសំរេចទងស្ដាំខាងលិច ។

ហើយស្ដេចព្រះរាជដំណើរទៅប្រថាប់នៅព្រះពន្លាក័ក នៅទីទួល លាកព្រែពួន ហើយទ្រង់ធ្វើបុណ្យបញ្ចុះសីមាវេរដល់សង្ឃ រួចទ្រង់ វេរទីដីស្រែឥតពលស់សម្រាប់វត្តថ្វាយព្រះរតនត្រ័យរួចស្រេច ទ្រង់ បញ្ញត្តឲ្យហៅថាវត្តព្រែពួន ក្រោយគមកគេហៅថាវត្តព្រែពួចលុះដល់ សព្វថ្ងៃ ។

ស្ដេចព្រះរាជដំណើរពីវត្តព្រែពួនទៅទួល៤ជ្រុង ទ្រង់ប្រថាប់ នៅព្រះពន្លាក័តស្ដេចឲ្យនិមន្តភិក្ខុសង្ឃមកទ្រង់ធ្វើបុណ្យបញ្ចុះសីមា វេរ ប្រគេនរួចស្រេចទ្រង់បញ្ញត្តឲ្យហៅថាវត្ត៤ជ្រុង អំណើះឈលគមកគេ ហៅថាវត្តទ្រនំជ្រុងវិញ ។

ស្ដេចព្រះរាជដំណើរចេញពីវត្តទ្រនំជ្រុង ទៅព្រះពន្លាក័តត្រង់ តន្លែងព្រះវរជននីទ្រង់ទតឃើញមេគោបំបៅកូន ទ្រង់ឲ្យនិមន្តភិក្ខុ សង្ឃមកគង់ចាំស្រោ ទ្រង់ធ្វើបុណ្យបញ្ចុះសីមាតាមព្រះពុទ្ធានុញ្ញាតវេរ

បរគេនសង្ឃ ទ្រង់ទេរដីស្រែទឹកពលទុកសម្រាប់វត្តថ្វាយព្រះរតនត្រៃ ទ្រង់បញ្ញត្តឲ្យហៅថាវត្តកេងកោ ។

## ទ្រង់ព្រះរាជទានយសស័ក្តិមន្ត្រីរាជការ

កាលស្ដេចព្រះរាជដំណើរចេញពីវត្តកេងកោ ទៅដល់ព្រៃគោក បំបុកកន្ទៃត្រកំពេញ ទ្រង់មានព្រះបន្ទូលឲ្យមន្ត្រីសង់ព្រះពន្លាក៏គង់នៅទីនោះរួចទ្រង់ព្រះមេត្តាប្រោសខុំរាជការ ៖ ដែលមានគុណបំណាច់ខន្ធ ដែនដីឲ្យបានឡើងស័ក្តិយស ដូចមានឈ្មោះតទៅនេះ;

ចៅពញាកក្តីសង្គ្រាម (ហុក) ឲ្យឡើងយសស័ក្តិជាឧកញ៉ាយមរាជ ។

ចៅពញាមន្ត្រីសង្គ្រាម (សួស) ឲ្យឡើងយសស័ក្តិជាឧកញ៉ាវាំង តែចៅពញាមន្ត្រីសង្គ្រាមក្រាបទូលសុំព្រះរាជទានធ្វើតែត្រឹមចៅហ្វាយស្រុកទ្រៃត្របាទដែលជាស្រុកកំណើត ក៏ទ្រង់ប្រោសព្រះរាជានុញ្ញាតតាមសុំ ។

អគ្គហ៊ិនហោមស្នេហានុជិត (ជូរ) ជាឧកញ៉ាចក្រី ។

ហ៊ិន (គម) ជាឧកញ៉ាកជរេជះ ។

ហ៊ិនជំនិតភក្តីសាទ្រង់ (ពេជ) ជាឧកញ៉ាកំង ។

ចៅពញា (ឡុង) ជាឧកញ៉ាក្រឡាហោម ។

ចៅពញា (ពៅ) ជាឧកញ៉ាមហាទេព ។

ចៅពញា (ឆយ) ជាឧកញ៉ាមហាមន្ត្រី ។

ហ៊ិន (សុខ) ជាឧកញ៉ាវង្សាអគ្គរាជ ។

ហ៊ីន (គាំ) ជាឧកញ៉ាធិរាជវង្សា ។

ហ៊ីន (ឡេង) ជាឧកញ៉ាមន្ត្រីនាយក ។

ដល់ថ្ងៃក្រោយមកឧកញ៉ាយមរាជ (ហុក) ក្រាបបង្គំទូលថាទូលព្រះបង្គំជាខ្ញុំចាស់ជរាណាស់ហើយ នឹងទ្រាំធ្វើរាជការយមរាជតទៅទៀតពុំបានដោយក្រសួងនេះមានតែកាប់សម្លាប់ជានិច្ច នឹងមិនរួចខ្លួនអំពីអបាយភូមិ ទូលព្រះបង្គំជាខ្ញុំសុំថ្វាយក្រាបសុំព្រះរាជទានលាឈប់ពីមុខក្រសួង សូមទ្រង់តាំងអ្នកដទៃដែលមានស្មារតីស្វាហាប់នោះវិញ ។ ក៏ទ្រង់ព្រះរាជានុញ្ញាតរួចទ្រង់តាំង ហ៊ីន (គល់) ជាឧកញ៉ាយមរាជ ។ ស្តេចទ្រង់ថ្វាយមុខងារសម្រាប់ឧបយោរាជ ទៅសម្តេចព្រះវររាជជននីទាំងអស់ ។

ថ្ងៃមួយ សម្តេចព្រះវររាជជននី ទ្រង់មានព្រះសវនីយ៍ នឹងព្រះបាទសម្តេចព្រះជ័យចេស្តាថា ឧកញ៉ាយមរាជ (ហុក) ដែលលាឈប់ពីរាជការនោះ មានគុណបំណាច់នឹងផែនដីច្រើនណាស់ គួរបិញ្ចូមវិញឲ្យពេញចិត្ត ដើម្បីឲ្យខ្ញុំរាជការទាំងពួងយកជាបែបយ៉ាងតទៅ ។

ទើបព្រះបាទសម្តេចព្រះជ័យចេស្តា ទ្រង់ព្រះមេត្តាប្រោសតាំងទៅពញាកត្តិសង្គ្រាម (ហុក) ឲ្យឡើងយសស័ក្តិជាក្រឡាពាសហ្លួងស័ក្តិ ១០ហ៊ូពាន់ដដែល ហើយទូលគាល់ឲ្យអង្គុយស្មើនឹងសេនាបតីហើយប្រោសព្រះរាជទានដីស្រែព្រៃព្រឹង ក្នុងខេត្រភ្នំពេញ ឲ្យធ្វើជាភូមិនៅ ។

(មានត)

ឥណ្ឌវគ្គបរិយាយ

# ព្រះគ្រូមហាបទុម អាយ-ស៊ុន រៀបរៀង

(តមកទំព័រ)

ទីយមួយទៀត ពោលពិតជាហេតុនៃសាមគ្គីរស ដោយធ្វើប្រយោជន៍ដល់គ្រួសារឲ្យសម្រេចបាន សមនឹងព្រះពុទ្ធដីកាដែលទ្រង់ត្រាស់ទុកថា សព្វំ ភ្នាក់ សាធុតរំ រសានំ ពាក្យសង្ខេបរសដ៏ប្រសើរក្រៃលែងជាងរសទាំងឡាយ ។ អធិប្បាយថា រសនៃអាហារទាំងពួងរមែងជាទីត្រូវចិត្តរបស់មនុស្សសត្វទាំងនេះណាទៅ ក៏ពិតមែន ប៉ុន្តែរសអាហារនោះជាទីត្រូវចរបស់មនុស្សសត្វទាំងនេះបានដោយពេលដោយខណៈខេ ហើយប្រែនៃញ៉ាំងទោសទុក្ខឲ្យកើតទៅវិញក៏មាន ដូចរសអាហារដែលប្រឆាំងដោយរសជាតិឆ្ងាញ់ពិសាណាស់ បើបុគ្គលបរិភោគប្រែនលើសបន្ទុកហើយក៏ត្រឡប់ជាឲ្យទុក្ខលំបាកស្មើនៃទីនឹងស្លាប់ក៏សឹងមាន ចំ-ណែកឯរសអាហារដែលមិនឆ្ងាញ់ពិសា គឺរសអាហារគ្រាក់ស្មោកគ្រោក ឆលថេបុគ្គលលិទ្ធកក្ស បរិភោគទៅពេលណា ក៏រមែងបានទទួលផលតីសម្ដីកាក់ផ្សេងៗ ចំពោះខ្លួនក្នុងពេលនោះក៏មាន រូបរមែងរសបត្តិមុខជារសអាហារទាំងពីរប្រភេទនេះ ជាគ្រឿងបន្ទុំជាគ្រឿងប្រមូលមកនូវសេកា-ទុក្ខឲ្យកើតឡើងកន្លងបច្ចុប្បន្នកាល និងសម្បរាយិកកាល ។ ចំណែកខាងរសគឺសច្ចៈ រមែងជាទីចាប់ចិត្តរបស់បុគ្គលគ្រប់ជាតិគ្រប់ជាន់ មិនបាន

ទិយេមថាជាតិអ៊ីទិមួយឡើយ   ព្រោះសច្ចវាចាជាធម៌ដែលសង្គ្រោះណាផុន តែនិកបក់កាន់ប្រើជាទិន្នូរ   ឯរសរបស់សច្ចវាចាបានផលធម្មជាតដែលធ្វើចិត្តរបស់គួរពោលសច្ចៈឲ្យរីករាយ;  រសរបស់សច្ចវាចានេះ  បើបុគ្គលណាមួយបានទទួលក្រេបផឹកហើយ   បុគ្គលនោះរមែងមិនមានសេចក្ដីទុក្ខវេទនា  ព្រោះសច្ចវាចាមិនមានរសអាក្រក់   មានតែរសជាតិល្អតែម្យ៉ាងប៉ុណ្ណោះ  បើទុកណាជាបានលិទ្ធភក្សក្រេបផឹកឲ្យប្រែនយ៉ាងណាក្ដី  ចំផុតមណ្ឌលឲ្យកើតសេចក្ដីទុក្ខលំបាកដូចជារសអាហារដទៃ ១ ឡើយ  បានជាព្រះដ៏មានបុណ្យទ្រង់ត្រាស់ទុកថា   សច្ចំសេចក្ដីពិតជារសប្រសើរលែងជាងរសទាំងឡាយ ៗ  ន័យមួយទៀត  សម្រាប់បុគ្គលនឹងបាននូវកិត្តិស័ព្ទល្បីខ្ចរខ្ចាយឮទៅក៏ដោយសារសច្ចធម៌  សមនឹងពុទ្ធភាសិតថា  សច្ចេនកិត្តិំ បប្បោតិ "ពួកជនរមែងមានកិត្តិស័ព្ទពីរោះពីសារដោយសច្ច" ៗ អធិប្បាយថា   បុគ្គលដែលមានកេរ្តិ៍ឈ្មោះល្អខ្ទរខ្ទាយសព្វាយទូទៅបានទាំងផ្លូវលោក  ទាំងផ្លូវធម៌ក៏ត្រូវស្រាយកំឡាំងសច្ចធម៌  បើវៀរចាកសច្ចធម៌ហើយមិនអាចប្រព្រឹត្តទៅបានឡើយ  ដ្បិតរូបរមសេចក្ដីមធ្យមគឺសច្ចធម៌នេះជាឧបាយញ៉ាំងសត្វក្នុងត្រកូលឲ្យដល់នូវអមតបុរី ៗ  ពុទ្ធាទិបណ្ឌិតឃើញអំណាចប្រយោជន៍នៃសច្ចៈយ៉ាងនេះ   ទើបទូន្មានប្រៀនប្រដៅឲ្យបុគ្គលមានសច្ចៈ ដល់គ្នានឹងគ្នា  ឲ្យផ្ដិតកាយវាចាចិត្តក្នុងសច្ចៈតែម្យ៉ាង  ហេតុនេះទើបសារពោលពាក្យសត្យ  សាធុជនត្រូវប្រែបឲ្យកើតឡើងក្នុងសន្តាន ៗ

## ៣– ក្រោធាភិភវៈ

### "ការគ្របសង្កត់សេចក្ដីក្រោធ"

សេចក្ដីប្រែកនៃចិត្តដោយអំណាចនៃទោសៈ ព្រោះបដិឃៈគឺសេចក្ដីទាំងទប់ឬការទាស់អារម្មណ៍បង្អៀតចិត្ត ហៅថាសេចក្ដីក្រោធ ។ សេចក្ដីក្រោធនេះ តែងកើតឡើងដោយអាស្រ័យសត្វនិងសង្ខារជាដើមហេតុ ធ្វើឲ្យបុគ្គលក្ដៅក្រហាយទៅតាមអំណាច ព្រោះមិនបានពិចារណាឲ្យដឹងដើមចុងនៃហេតុ បើគប់ហាឲ្យមានៈនិងទិដ្ឋិចូលគ្របសង្កត់ចិត្ត ។ សេចក្ដីក្រោធនេះមាននៅក្នុងសន្ដានបុគ្គលណាហើយ រមែងនាំឲ្យបុគ្គលនោះឲ្យដល់សេចក្ដីវិនាសបាន ព្រោះជាហេតុនាំឲ្យប្រទូស-រ៉ាយបៀតបៀនចំពោះអ្នកដទៃ ក្រៅពីនោះរមែងបង្កសេចក្ដីអន្ដរាយនឹងពៀរឲ្យកើតឡើងចំពោះខ្លួន ។ អ្នកដែលមានសេចក្ដីក្រោធជាម្ចាស់ហើយ សូម្បីមិនសំដែងចេញតាមផ្លូវកាយវាចាក្ដី ក៏គង់តែងមានទោសផលខ្លួនពុំខាន គឺរមែងធ្វើចិត្តរបស់ខ្លួនឲ្យកើតច្រល្អក់ជាទុក្ខ កាលបើមិនបានឱកាសនឹងប្រទូសរ៉ាយដល់ជនដទៃតាមប្រាថ្នាខ្លួន ក្នុងពេលណាហើយ តែងមានអំណោយផល គឺសេចក្ដីមិនសប្បាយចិត្តកើតចំពោះខ្លួន ទោះបីនឹង ដេក ដើរ ឈរ អង្គុយ ក៏មិនស្រួល ក្នុងទីបំផុតរាងកាយក្នុងវេលាដែលសេចក្ដីក្រោធគ្របសង្កត់នោះ រមែងសៅហ្មងប្រែបាត់អាការប្រក្រតី នេះឯងជាទោសរបស់សេចក្ដីក្រោធចំណែកមួយ ។

ការធ្វើកិច្ចណាៗ ដោយសេចក្ដីក្រោធ រមែងឲ្យទោសដោយប្រការទាំងពីរ ពួង ទើបលោកសំដែងទោសនៃសេចក្ដីក្រោធ ប្រៀបធៀបទុកដូច ជាស្នឹមនៃគ្រឿងសស្ត្រាវុធ ដោយមានភាសិតថា កោធោ សត្ថ-មលំ លោកេ "សេចក្ដីក្រោធទុកដូចជាស្នឹមនៃគ្រឿងសស្ត្រាវុធក្នុងលោក" មានអធិប្បាយថា ធម្មតាច្រែះឬស្នឹមដែលកើតឡើងអំពីដែក រមែងត្រឡប់ស៊ីចំផ្ញាញដែកនោះឲ្យវិនាសទៅយ៉ាងណា សេចក្ដីក្រោធ ដែលកើតឡើងអំពីរូបបុគ្គលមួយៗ ក៏ត្រឡប់ជាគ្រឿងបៀតបៀនម្ចាស់ខ្លួន ឲ្យដល់នូវសេចក្ដីវិនាសវិញបានយ៉ាងនោះដែរ ។ ហេតុនេះទើបជាទោស ដែលគួរលះបង់ មិនគួរឲ្យកើតឡើងក្នុងខន្ធសន្តាន ឯការដែលនឹងលះ សេចក្ដីក្រោធនោះត្រូវការស្រ័យគំនិតសតិខន្តីសម្បជញ្ញៈ គឺតាំងស្មារតី នឹងតាំងខ្លួនទាន់ដោយឧបាយោនិសោមនសិការៈ ក្នុងផ្លូវដែលត្រូវ យ៉ាងនេះទើបលះបាន ដើម្បីកំចាត់ចោលនូវពៀរទាំងឡាយ ព្រោះពៀរទាំងនោះ មិនមែនរម្ងាប់ដោយការចងពៀរតបទេ សមដូច គាថាជាពុទ្ធភាសិតថា:

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ

អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ

សេចក្ដីថា ក្នុងកាលណាៗក៏ដោយ ពៀរទាំងឡាយមិនដែលរម្ងាប់ ដោយការចងពៀរតបឡើយ រមែងរម្ងាប់បានដោយការមិនចងពៀរ របៀប

នេះជាប្រវេណីរបស់អ្នកប្រាជ្ញមានមកអំពីបុរាណកាល ។ អ្នកមានចិត្ត ដែលសតិនឹងសម្បជញ្ញៈប្តូរគ្រប់គ្រង រមែងបានប្រយោជន៍សោមនស្សភាព តាមផ្លូវប្រពៃ រមែងលះបង់សេចក្តីក្រោធបានដោយងាយ អ្នកមានចិត្ត ដែលសតិនឹងសម្បជញ្ញៈមិនបានទៅគ្រប់គ្រង មិនបានប្រយោជន៍សោម-នស្សការកន្លងផ្លូវប្រពៃ ចិត្តរមែងប្រព្រឹត្តទៅតាមអារម្មណ៍ផ្សេងៗ សេចក្តីក្រោធក៏កើតឡើងរហ័សហើយក្រទឹងលះបានផង ប្រៀបដូចរថដែលគ្មាននាយសារថី ឬមានសារថីមិនប៉ិនប្រសប់ រមែងនាំអ្នកបរបំភ្លៃ មិនត្រង់ក្នុងទីផ្លូវផ្ទាល់ រមែងធ្វើសេចក្តីវិនាសឲ្យកើតឡើងដល់ខ្លួនខ្លះ ដល់មនុស្សដទៃខ្លះ ចំណែករថដែលមានសារថីឆ្លាតឆ្លាស់ រមែងលឿនទៅត្រង់មិនខុសផ្លូវ ហើយមិនធ្វើអន្តរាយដល់ខ្លួននិងអ្នកដទៃឡើយ ការញុំាងប្រយោជន៍ឲ្យសម្រេច សេចក្តីនេះយ៉ាងណា ការប្រព្រឹត្តទៅនៃបុគ្គលគ្រប់រូបក៏យ៉ាងនោះដែរ; បុគ្គលដែលទប់សេចក្តីក្រោធបានព្រះទ្រង់ញ្ញាណឲ្យឈ្មោះថាសារថីយ៉ាងឯក សមដូចទិពន្ធពុទ្ធភាសិតថា

យោ វេ ឧប្បតិតំ កោធំ រថំ ភន្តំវ ធារយេ
តមហំ សារថឹ ព្រូមិ រស្មិគ្គាហោ ឥតរោ ជនោ

សេចក្តីថា បុគ្គលឯណា ឃាត់សេចក្តីក្រោធដែលកើតឡើងបានដូចគេទប់រថកំពុងលឿនឲ្យទៅនឹងថ្កល់ បុគ្គលនោះតថាគតហៅថាជាសារថី បុគ្គលដទៃក្រៅពីនេះ ឈ្មោះថាគ្រាន់តែជាអ្នកកាន់ខ្សែប៉ុណ្ណោះ ។

អធិប្បាយថា ព្រះបរមសាស្ដា ទ្រង់សរសើរបុគ្គលអ្នកឃាត់នូវ
សេចក្ដីក្រោធរបស់ខ្លួនបានថាជាសារថីយានដ៏ឯក ព្រោះជាអ្នកប្រៀន
ប្រដៅខ្លួនឯងបាន ចំណែកសារថីទាំងឡាយដែលបរកេវរថជាដើម គ្រាន់
តែមានឈ្មោះថាជាអ្នកកាន់ខ្សែបរបុណ្ណោះ មិនបានឈ្មោះថាជាសារថី
ពិតៗនោះឥតគតិមានឡើយ ។ សេចក្ដីក្រោធនេះជាទោសដែលគួរលះ
បង់ចោលស្រឡះ ព្រោះការលះបង់បានជាហេតុនាំមកនូវប្រយោជន៍
ដ៏ក្រៃលែងជ្រះថ្លាប្រកបដោយមេត្តាចំពោះអ្នកដទៃ គឺអំពីនោះរមែងធ្វើចិត្ត
ឲ្យជាសុខ កាលបើចិត្តតាំងនៅជាសុខហើយ កាយក៏រមែងជាសុខដែរ
តាមដែរ សមដូចភាសិតថា

កោធំ ឃត្វា សុខំ សេតិ កោធំ ឃត្វា ន សោចតិ

សេចក្ដីថា សម្លាប់សេចក្ដីក្រោធចេញបាន រមែងដេកជាសុខ
សម្រាន្ត សម្លាប់សេចក្ដីក្រោធចេញបាន រមែងមិនសោយសោក ។

ហេតុនេះគួរគប្បសង្កត់បំបាត់កំចាត់បង់សេចក្ដីក្រោធ ជាហេតុ
នាំឲ្យបាននូវសេចក្ដីសុខដ៏ប្រពៃ ជាធម៌ដែលសាធុជនគួរប្រតិបត្តិរៀងៗក្នុង
ខ្លួនសន្ដាន ។ រូបមធម៌៧ប្រការគឺ ការចិញ្ចឹមមាតាបិតា ១ ការប្រព្រឹត្ត
ឱនលំទោនគោរពដល់ជេដ្ឋបុគ្គល គឺអ្នកធំក្នុងត្រកូល ១ ការពោលសំដី
ផ្អែមដែលនាំឲ្យកើតមិត្រសន្ថវៈ ១ ការលះបង់ការស៊ិតសៀត ១ សេចក្ដី
ត្រេកអរក្នុងការបរិច្ចាគទាន ១ ការពោលពាក្យសត្យ ១ ការគ្រប់សង្កត់

សេចក្ដីក្រោធបាន ១ ។ ព្រះមហាមុនីទ្រង់សរសើរថា ធម៌ ៧ ប្រការនេះមាននៅក្នុងសន្ដាននៃជនឯណា ទេវតាជាន់តាវតឹង្សទាំងឡាយពោលសរសើរជននោះថា ជាសប្បុរសដោយពុទ្ធភាសិតជាបាវចនៈថា

មាតាបេត្តិភរំ ជន្តុំ កុលេ ជេដ្ឋាបចាយិនំ
សណ្ហំ សខិលសម្ភាសំ បេសុណេយ្យប្បហាយិនំ
មច្ឆេរវិនយេ យុត្តំ សច្ចំ កោធាភិភុំ នរំ
តំ វេ ទេវា តាវតិំសា អាហុ សប្បុរិសោ ឥតិ

សេចក្ដីថា ទេវតាជាន់តាវតឹង្សទាំងឡាយពោលសរសើរនូវនរជន អ្នកចិញ្ចឹមមាតាបិតា, មានសម្មាគារវៈនូវលំដាប់ ចំពោះជេដ្ឋបុគ្គល, ពោលពាក្យទន់ផ្អែមនាំឲ្យកើតមិត្រសន្ថវៈ, លះបង់នូវពាក្យស៊ីចសៀត, ប្រកបខ្លួនក្នុងការបំបាត់មច្ឆរិយៈ គឺសេចក្ដីកំណាញ់, មានពាក្យទៀងត្រង់ ត្រួតសង្កត់សេចក្ដីក្រោធថាជាសប្បុរស ។

ម្យ៉ាងទៀត លោកបានពោលទុកថាសក្កទេវរាជ (ព្រះឥន្ទ្រ) ដែលបានជាស្ដេចនៃទេវតាទាំងឡាយក្នុងតាវត្រឹង្ស ក៏ព្រោះបានសមាទាននូវធម៌ ៧ ប្រការនេះឲ្យបរិបូណ៌ក្នុងសន្ដាន ទើបធម៌នេះឯងឈ្មោះថាវត្តបទ ។

គុណធម៌ទាំងឡាយដែលបាននិយាយហើយនោះ រមែងមានគុណប្រយោជន៍ដ៏ប្រសើរ គឺអាចញ៉ាំងបុគ្គលឲ្យបានជួបប្រទះនូវសេចក្ដី

សុខសម្រិទ្ធ ព្រោះខ្លួនដល់ព្រមដោយកុសលបរិយេសម្បត្តិដែលជាបុណ្យដ៏ប្រសើរហើយរមែងសប្បាយរីករាយក្នុងលោកទាំងពីរ សមតាមទេសនានៃព្រះមុនីសាស្តាចារ្យថា :

ឥធ នន្ទតិ បេច្ច នន្ទតិ កតបុញ្ញោ ឧភយត្ថ នន្ទតិ

បុញ្ញំ មេ កតន្តិ នន្ទតិ ភិយ្យោ នន្ទតិ សុគតឹ គតោ –

សេចក្តីថា បុគ្គលដែលបានធ្វើបុណ្យទុកហើយ រមែងរីករាយក្នុងលោកនេះ លុះរំលាយខ្លួនលះលោកនេះទៅហើយក៏រមែងរីករាយទៀតគឺរីករាយក្នុងលោកទាំងពីរ រមែងរីករាយដោយគិតថា អាត្មាអញបានធ្វើបុណ្យទុកហើយ លុះទៅកាន់សុគតិភពតែងរីករាយជាភិយ្យោភាព ។

ហេតុនេះធម៌ទាំង ៧ ប្រការដូចបានពោលហើយ ជាគុណញុំាងប្រយោជន៍ឲ្យសម្រេចទាំងក្នុងបច្ចុប្បន្ននិងសម្បរាយិកភព; សាធុជនទាំងឡាយកាលបានស្តាប់ពុទ្ធភាសិតនេះហើយ គប្បីតាំងខ្លួនទុកក្នុងធម៌ទាំង ៧ ប្រការ ជាគុណគួរសមាទានឲ្យកើតមានឡើងទីជាបុញ្ញទានដ៏ប្រពៃ ហើយនេះទើបឈ្មោះថាជាអ្នកស្វែងរកទ្រព្យដ៏ប្រសើរតាមន័យពុទ្ធភាសិតដូចបានពណ៌នាមកហើយ ។

ចប់គិហិវត្តបរិយាយតែប៉ុណ្ណេះ ។